

# មគ្គុទេសអំពី

# សេរីភាព ការទទួលបានព័ត៌មានជាមុន និង ការយល់ព្រម

OXFAM

**បោះពុម្ព នៅខែ មិថុនា ឆ្នាំ២០១០**
អុកស្វាម អូស្ត្រាលី
ទីក្រុង Melbourne ប្រទេស Australia
ផ្លូវ 132 Leicester,
Carlton 3053
Victoria
Australia
ABN 18 055 208 636
ទូរសព្ទ័: +61 3 9289 9444
គេហទំព័រ: www.oxfam.org.au

**អ្នកនិពន្ធ:** Christina Hill, Serena Lillwhite and Michael Simon
**អ្នកកែសំរួល:** Talia Eilon and Maureen Bathgate
**អ្នក វិចិត្ររូប:** Dominique Fella
**អ្នករៀបប្លង់:** Paoli Smith
**ផលិតកម្មបោះពុម្ព:** David Edgley
**អ្នកបោះពុម្ព:** McLaren Press
**អ្នកចែកចាយ:** Chelsea Huggett and Claire Hussin

## សេចក្តីថ្លែងអំណរគុណ

អុកស្វាម សូមថ្លែងអំណរគុណ និង អរគុណ ដល់អង្គការ និង មនុស្សជាច្រើន ដែលបានផ្តល់យោបល់ និង ណែនាំក្នុងការរៀបចំការបោះពុម្ពនេះ ។ ជាពិសេស យើងសូមថ្លែងអំណរគុណ ចំពោះយោបល់ និង គំនិតពីកម្មវិធីប្រជាជននៅតំបន់ព្រៃឈើ អង្គការទន្លេអន្តរជាតិ វិទ្យាស្ថានធនធានពិភពលោក អង្គការអុកស្វាមអាមេរិច ទីភ្នាក់ងារកាតូលិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ និង កតិកាសញ្ញា ជនជាតិដើមភាគតិចអាស៊ី ។ យើងក៏ថ្លែងអំណរគុណផងដែរចំពោះមូលនិធិ Planet Wheeler ចំពោះការគាំទ្រផ្នែកមូលនិធិរបស់គេ ។



**កន្លែងសំរាប់ អង្គការក្រៅរដ្ឋាភិបាលបិនតែម**

## ឧបសម្ព័ន្ធ ទី ៣ៈ

### វដ្តនៃគំរោង

មិនមែនគំរោងទាំងអស់ដូចគ្នានោះទេ ។ ទោះជាយ៉ាងណាក៏ដោយ គំរោងនិមួយៗអាចមានដំណាក់កាលដូចខាងក្រោម ។ ដ្យាក្រាមនេះជាលក្ខណៈទូទៅ នៃវដ្តគំរោងមួយ ។ វាមានគោលបំណងជួយអ្នកអោយយល់ ពីដំណើរការចូលរួម ទៅពេលដែល ចូលរួមជាមួយ អ្នកអភិវឌ្ឍន៏គំរោង ។

**សកម្មភាពៈ** តើអ្វីដែលកើតឡើងជារឿយៗ នៅក្នុងដំនាក់កាលនិមួយៗ នៃគំរោងធំមួយ នៅក្នុងការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធធំៗ ។

**សកម្មភាពអនុវត្តល្អ ក្នុងការអោយសហគមន៏ចូលរួមៈ** នេះជាអ្វីដែល អ្នកអភិវឌ្ឍន៏គំរោង គួរតែធ្វើដើម្បីធានា ថា សហគមន៏ត្រូវបានចូលរួម នៅរាល់ដំណាក់កាលទាំងអស់នៃគំរោង ។

| ដំណាក់កាលនៃគំរោង | សកម្មភាព / សកម្មភាពអនុវត្តល្អ |
|---|---|
| ទស្សនទាន គំរោង | › ការកំណត់ឱកាសនៃគំរោង<br>› ការអនុញ្ញាតិ ត្រូវបានទទួលពី រដ្ឋាភិបាលមូលដ្ឋាន<br>› ការរុករក រ៉ែ/ការអង្កេត ចំពោះការធ្វើទំនប់ |
| | › ការអោយសហគមន៏ចូលរួម<br>› ការវិភាគហានីភយ័គំរោង រួមមាន បញ្ហាអ្នកដែលពាក់ពន្ធ័<br>› ចំពោះគំរោង ដែលស្មុកស្មាញ បង្កើតវេទិការ ការធ្វើផែនការ អ្នកដែលពាក់ពន្ធ័ |
| ការសិក្សាពីភាពជោគជយ័ និង ការធ្វើផែនការគំរោង | › អ្នកអភិវឌ្ឍន៏ធ្វើផែនការ គំរោង<br>› ការប៉ាន់ស្មានពី ឥទ្ធិពល សង្គម និង បរិស្ថាន (ESIA) ត្រូវបានអនុវត្ត |
| | › ការអង្កេតសិទ្ធិមនុស្សក៏គួរតែត្រូវបានធ្វើឡើង<br>› ESIA គួរមានផែនការ កាត់បន្ថយឥទ្ធិពល<br>› ចរចារកិច្ចព្រមព្រៀង ផលប្រយោជន៏ឥទ្ធិពលជាមួយ សហគមន៏<br>› រៀបចំជាមួយសហគមន៏ នូវនិតិវិធីដោះស្រាយសារទុក្ខ សហគមន៏ |
| ការសាងសង់ | › អ្នកអភិវឌ្ឍន៏ ចាប់ផ្តើមកសាង លទ្ធភាពផ្សេងៗ<br>› នេះរួមមាន ការទិញដី ការសំអាតដី ការរើទីលំនៅរបស់សហគមន៏ ។ល ។ |
| | › សហគមន៏កត់សំគាល់ សកម្មភាពសាងសង់ និង ផ្តល់យោបល់ នៃការផ្លាស់ប្តូរ<br>› មានវិធីសាស្ត្រដោះស្រាយពាក្យបណ្តឹង<br>› សហគមន៏បានផ្តល់ពត៌មាន ពីកម្មវិធី គ្រប់គ្រងឥទ្ធិពលសង្គម និង បរិស្ថាន |
| ការប្រតិបត្តិការណ៍ | › អន្តរកាលពី ការសាងសង់ ទៅការប្រតិបត្តិការណ៏<br>› ប្រពន្ធ័គ្រប់គ្រងប្រតិបត្តិការណ៏ចាប់ផ្តើម |
| | › បន្តការបើកចំហរ ប្រឹក្សាចំពោះសហគមន៏ដែលទទួលរងឥទ្ធិពល<br>› ការពារគ្រោះថ្នាក់ និង ការបំពុល ដោយយោងទៅតាម ផែនការគ្រប់គ្រងសង្គម និងបរិស្ថាន<br>› ការដោះស្រាយពាក្យបណ្តឹង សហគមន៏ជាបន្តបន្ទាប់ |
| ការកាត់បន្ថយទំហំ ការដកហូតសិទ្ធិ ការឈប់អនុវត្ត | › គំរោងមកដល់ទីបញ្ចប់<br>› អ្នកអភិវឌ្ឍន៏គំរោង ចាប់ផ្តើមដកចេញ ឬ បិទការងារ |
| | › ផែនការអនុវត្ត ត្រូវធ្វើការកែសំរួល និង អោយមានបច្ចុប្បន្នភាព ដូចដែលអ្នកពាក់ពន្ធ័បានផ្លាស់ប្តូរ នៅអំឡុងពេលនៃគំរោង<br>› ធ្វើផែនការ និង អនុវត្ត ការប្រឹក្សាសហគមន៏ (ដូចនៅក្នុងដំណាក់កាល ការសិក្សាលទ្ធភាព)<br>› គួរតែជាផ្នែកនៃ ESIA |

FPIC ប្រទះនៅក្នុងចំនុច ការធ្វើសេចក្តីសំរេចចិត្ត សំខាន់ៗនៃគំរោង



# បុព្វកថា

អ្នកស្វាម ទទួលស្គាល់ បញ្ហា សុវត្ថិភាព និង ការប្រឈមផ្សេងៗ ដែលសហគមន៍ និង ប្រជាជនជាច្រើន ជួបប្រទះ ក្នុងការធានាអោយសិទ្ធិ និង កង្វល់របស់គេ ត្រូវបានទទួលស្គាល់ និង លើកឡើង ។នៅក្នុង ការប្រើ ឯកសារណែនាំនេះ សហគមន៍ត្រូវបានផ្តល់ជាយោបល់ក្នុង ការយកចិត្តទុកដាក់ ដោយមានការ ប្រុងប្រយត្ន័ចំពោះ ហានិភ័យ និង សុវត្ថិភាពណាមួយដែលគេអាចជួបប្រទះ ។



## គោលបំណងនៃ ឯកសារណែនាំ អំពី សេរីភាព ការទទួលបានពត៌មានជាមុន និង ការយល់ព្រម

ឯកសារណែនាំ អំពី សេរីភាព ការទទួលបានពតិមានជាមុន និង ការយល់ព្រម (FPIC) វាផ្តល់ពតិមាន ជាមូលដ្ឋានអំពី FPIC និង អំពីរបៀបដែលអាចជួយសហគមន៏ អោយមានយោបល់អំពីគំរោងអភិវឌ្ឍន៏ការធ្វើទំនប់ ការជីករ៉ែ និងគំរោងហេដ្ឋារចនាសម្ពន្ធ័ធំៗ ដែលអាចមានឥទ្ធិពលមកលើពួកគាត់ក្នុងបែបផែនណាមួយ ។

យើងទាំងអស់គ្នា មានសិទ្ធិក្នុងការសំរេច លើអ្វីដែលកើតឡើងនៅលើដីរបស់យើង ។ គោលការណ៏នេះ ត្រូវបានការពារដោយ ច្បាប់សិទ្ធិមនុស្សជាអន្តរជាតិ ដូចជា " ប្រជាជនទាំងអស់មានសិទ្ធិក្នុងការ សំរេច ដោយខ្លួនគេ" និង ផ្សារភ្ជាប់ សិទ្ធិនេះទៅនឹងការកំណត់ ដោយខ្លួនឯងថា" ប្រជាជនទាំងអស់ មានសិទ្ធិ ក្នុងការបញ្ចុះបញ្ចូល ការអភិវឌ្ឍន៏ សេដ្ឋកិច្ច សង្គម និង វប្បធម៌របស់គេ ដោយសេរី " ។

គោលការណ៏នេះត្រូវបានរៀបចំឡើង ដើម្បីជួយ អង្គការដែលកំពុងជួយ សហគមន៏ ដោយទទួលរង ឥទ្ធិពលពីគំរោង អភិវឌ្ឍន៏ធំៗ ។ វាជាឧបករណ៏អនុវត្តមួយដែលបន្ថែមលើការសំរបសំរួល ពិភាក្សា រវាងសហគមន៏ ជាមួយអ្នកអភិវឌ្ឍន៏គំរោង រួមទាំងក្រុមហ៊ុន និង រដ្ឋាភិបាល ឬ អ្នកផ្តល់មូលនិធិ ។

គោលការណ៏ នេះមាន ៧ ជំហ៊ាន សំរាប់អនុវត្ត ដែលមានគោលបំណង ជួយដល់ សហគមន៏ ជនជាតិដើមភាគតិចដែលទទួលរងឥទ្ធិពល ដោយ គំរោងដើម្បីទាមទារ សិទ្ធិរបស់គេ ជាសមូហភាព ចំពោះ FPIC ។ វាក៏បានបង្ហាញ ពីគោលការណ៏ ដូចគ្នា ដោយប្រើប្រាស់ចំពោះ សហគមន៏ដែលទទួលរង ឥទ្ធិពលដោយគំរោងទាំងអស់ ។ វារួមបញ្ចូល ជាផ្នែកមួយដែលជាធនធាន សំរាប់ជួយដល់សហគមន៏ អោយយល់ ពីសិទ្ធិរបស់គេ ជាមួយ នឹង គន្លឹះ និង ពតិមានសំខាន់ៗ ។ គោលការណ៏នេះក៏មានសញ្ញា "ព្រមានខ្លះ" ដែលបង្ហាញពីអ្វីដែលមានការ ខុសឆ្គង និង ការលំបាក ដែលសហគមន៏អាចជួប ប្រទះ ។

## សេចក្តីផ្តើមពី FPIC

ជនជាតិដើមភាគតិច បានតស៊ូអោយមានការទទួលស្គាល់ សិទ្ធិនេះដោយរដ្ឋាភិបាលរបស់គេ និង សហគមន៏អន្តរជាតិព្រមទាំងក្រុមហ៊ុន ក្នុងការផ្តល់ ឬលើកកំពស់ការយល់ព្រម ចំពោះគំរោងអភិវឌ្ឍន៏ ។ សិទ្ធិនេះ ទាក់ទងផ្ទាល់ទៅនឹងសិទ្ធិ ជនជាតិដើមភាគតិច ក្នុងការគ្រប់គ្រង អនាគតរបស់គេ និង ប្រជាជន គេ ។ វាបានបញ្ជាក់ជាសិទ្ធិថា" ត្រូវផ្តល់ និង លើកកំពស់ ឯកសារណែនាំ អំពី សេរីភាព ការទទួល បានពតិមានជាមុន និង ការយល់ព្រម ចំពោះ សកម្មភាព ដែលមានឥទ្ធិពល មកលើដី និង ព្រំដែន រួមទាំង ធនធានធម្មជាតិរបស់ពួកគេ" ។

ជាសង្ខេប វាជា សេរីភាព ការទទួលបានពតិមានជាមុន និង ការយល់ព្រមឬ FPIC ជាភាសាអង់គ្លេស ។

សិទ្ធិនេះរមែងតែ ត្រូវបានបំពាននៅពេលដែលមានគំរោងអភិវឌ្ឍន៏ ធំៗ ដូចជា រ៉ែ ទំនប់វារីអគ្គិសនី ឬ ការធ្វើចំការឈើដាំ ។ ជនជាតិដើមភាគតិចរមែងត្រូវបានបំភ្លេច នៅ ក្នុងដំណើរការធ្វើផែនការ និង ការធ្វើសេចក្តីសំរេចចិត្តនៅក្នុងគំរោងទាំងនោះ ។ ជាលទ្ធផលវាអាចក្លាយ ជាការបង្ខិនបង្ខោច ។ ជនជាតិ ដើមភាគតិច និង សហគមន៏ ដែលទទួលរង ឥទ្ធិពលដោយគំរោង ទទួលរង ហានិភ័យ ដោយ ការបាត់បង់ ជារៀងរហូត ចំពោះការចិញ្ចឹមជីវិត និង វប្បធម៌របស់គេ ។ ដីអាចទទួលរងការខូចខាត ឬ យកទៅដោយមិនគិតពី ការយល់ព្រមរបស់គេ ។ ការផ្លាស់ប្តូរទីលំនៅរមែងតែត្រូវបានបង្ខិតបង្ខំទៅលើ សហគមន៏ ដោយ មិនមានការផ្តល់សំណងអោយបានសមស្រប ។

ទាំងនេះមិនគួរអោយមានការកើតឡើងទេ ។ ជនជាតិដើមភាគតិចត្រូវបាន ការពារពីស្ថានភាព ទាំងនេះដោយស្ថិតនៅក្រោមច្បាប់ អន្តរជាតិ និង សេចក្តីប្រកាស អង្គការសហប្រជាជាតិ ស្តីពី សិទ្ធិជនជាតិ ដើមភាគតិច (UNDRIP) ។ ការការពារ ក៏មានចំពោះ សហគមន៏ដែលទទួលរង ឥទ្ធិពល ដោយ គំរោង ផ្សេងទៀតដែរ ។ ជនជាតិដើមភាគតិច មានសិទ្ធិ ចូលរួមក្នុងការ សំរេចចិត្ត ណាមួយ ដែលមានឥទ្ធិពល ទៅលើ ដី ធនធាន ឬ ដែនដីរបស់គេ ។ ចំពោះគំរោង ដែលមាន ឥទ្ធិពលមក លើសហគមន៏ គេមាន សិទ្ធិក្នុងការផ្តល់ និង បដិសេធន៏ ការយល់ព្រម ដោយ មានសេរីភាព និង បានពតិមានជាមុន ។ គេមានសិទ្ធិទទួល បានការសំរេចចិត្តជាសមូហភាពតាម រយៈដំណើរការ ដែលកំណត់ និង សំរេច ដោយ ពួកគេផ្ទាល់ ។

ចំពោះ សហគមន៏ ដែលបានទទួលរងឥទ្ធិពលពីគំរោង តែ មិនមែនជាជនជាតិដើមភាគតិច ការចូលរួមដោយពេញលេញ និង មានប្រសិទ្ធិភាព នៅក្នុងការ ចរចារ និង ការធ្វើផែនការគំរោង របស់គេ ត្រូវតែបាន ទទួលការគាំទ្រ ។

## ឧបសម្ពន្ធ័ ទី ២:

## ទ្រង់ទ្រាយការងារសំរាប់ធ្វើការស្រាវជ្រាវ ច្បាប់មូលដ្ឋាន ស្តីពី FPIC

សំនួរ ទាំងនេះត្រូវបានរៀបចំឡើង ដើម្បីជួយអោយយល់ ថាតើ ការយល់ព្រម ដែលមានឥស្សរភាពជាមុន និង បានផ្តល់ពតិមាន ត្រូវបានការពារនៅក្នុងច្បាប់ជាតិ ក្នុងប្រទេសរបស់អ្នកដែរឬទេៈ

**១. តើប្រទេសរបស់អ្នក បានបង្ហាញពីការគាំទ្រ សេចក្តីប្រកាសរបស់សហប្រជាជាតិ ស្តីពីសិទ្ធិ ជនជាតិដើមភាគតិច ដែរឬទេ (UNDRIP)?**
ពិនិត្យមើលតារាងនៅទំព័រទី ៣០ ដើម្បីមើលថាតើ ប្រទេសរបស់អ្នកមាននៅក្នុងបញ្ជីគាំទ្រ UNDRIP ដែរឬទេ ។ បើសិនជាគ្មានទេ នោះត្រូវពិនិត្យមើល គេហទំព័រ សហប្រជាជាតិ www.un.org/esa/socdev/unpfii/

**២. តើមាន និតិកម្មណាមួយ នៅក្នុងច្បាប់ជាតិ របស់ប្រទេសអ្នកដែលបានផ្តល់ការគាំទ្រដល់ FPIC ដែរឬទេ?**

**បើមានៈ**
តើមាននិយាយថាដូចម្តេចខ្លះ?
មើលលំអិត នៅក្នុងនិតិកម្មដើម្បីរកមើល តើអ្វីខ្លះដែលត្រូវការនៅក្រោមច្បាប់នេះ ។
តើវាអនុវត្តចំពោះអ្នកណាខ្លះ?
ពិនិត្យមើល ថាតើនិតិកម្មអាច អនុវត្តចំពោះរាល់គំរោង ដែលមានឥទ្ធិពលមកលើសហគមន៏ ឬ ថាតើ មានភាពជាក់លាក់ចំពោះតែ ជនជាតិដើមភាគតិច ដែរឬទេ ។
តើនិតិវិធីអ្វី ដែលច្បាប់នោះត្រូវការ?
ប្រៀបធៀប ច្បាប់ប្រទេសរបស់អ្នក ជាមួយមាត្រា ៣២ របស់ UNDRIP ដើម្បីពិនិត្យមើលថាតើ ផ្នែកនិមួយៗរបស់ FPIC ត្រូវបានគ្របដណ្តប់ដែរឬទេ ។ មើលអោយគៀកកិត នៅលើនិតិវិធី ដែលច្បាប់បានសរសេរ ។

**បើគ្មានៈ**
តើនិតិកម្មណាមួយនៅក្នុងច្បាប់ជាតិ របស់ប្រទេសអ្នកដែលគាំទ្រដំណើរការប្រហាក់ប្រហែលគ្នាទៅនឹង FPIC?
មើលថាតើប្រទេសរបស់អ្នកមាន និតិកម្មដែលលើកឡើង ពីដំណើរការប្រហាក់ប្រហែលគ្នាទៅនឹង FPIC ដែរទេ ។
ទាំងនេះអាចរកឃើញនៅក្នុងច្បាប់ដែលទាក់ទងទៅនឹង ការអភិវឌ្ឍន៏ ហេដ្ឋារចនាសម្ពន្ធ័ ឧទាហរណ៏ ការធ្វើផែនការនិតិកម្ម ។
តើនិតិវិធីអ្វីដែល ត្រូវការនៅក្រោមច្បាប់?
មើលលំអិត នៅក្នុងដំណើរការ ដែលបានសរសេរ ។ តើផ្នែកណាខ្លះនៃ FPIC ដែលត្រូវការដោយច្បាប់? ឧទាហរណ៏ អាចមាន និតិវិធីប្រឹក្សាជាមួយ សហគមន៏ តំរូវការលើផែនការ តំរូវការនៃការធ្វើ ការប៉ាន់ស្មាន ឥទ្ធិពលសង្គម និង បរិស្ថាន ។

**៣. តើមានករណីណាមួយដែលច្បាប់ នៅក្នុងប្រទេសរបស់អ្នកគាំទ្រ ការយល់ព្រមដែលមានឥស្សរភាពជាមុន និង បានផ្តល់ពតិមាន (FPIC) ?**

**បើមានៈ**
តើតុលាការសំរេចចិត្តយ៉ាងដូចម្តេច?
មើលករណីផ្សេងៗ ដែលសហគមន៏ទទួលរងឥទ្ធិពលដោយគំរោង ទាមទារសិទ្ធិរបស់គេចំពោះ FPIC នៅក្នុងផ្នែកណាមួយៈ ការជីករ៉ែ ទំនប់ ការកាប់ឈើ ។ មើលលំអិតតើអ្វីដែលតុលាការ សំរេចដោយអានការវិនិច្ឆយ័របស់គេ ។
តើវាអាចអនុវត្តបានចំពោះករណីរបស់អ្នកដែរឬទេ ?
មើលកាលៈទេសៈ នៃករណីដែលប្រហាក់ប្រហែល នឹង ករណីអ្នក ។ អានអ្វីដែលតុលាការនិយាយ ។
តើហេតុផលប្រហាក់ប្រហែលនេះអាច អនុវត្តបាននៅក្នុង ស្ថានភាពរបស់អ្នកដែរឬទេ.

**បើគ្មានៈ**
តើមានករណីសិក្សានៃ គំរោងប្រហាក់ប្រហែល នៅក្នុងប្រទេសអ្នកដែរឬទេ?
បើសិនជាគ្មាន ករណីតុលាការទេ ស្រាវជ្រាវមើលតើសហគមន៏ផ្សេងទៀត មានទទួលរងផលប៉ះពាល់ ដោយគំរោងហេដ្ឋារចនាសម្ពន្ធ័ ដែរឬទេ ។ តើសកម្មភាពអ្វីដែលគេបានធ្វើ? វាអាចមានជាករណីសិក្សា ដែលអាចជួយអ្នកក្នុងការការពារ សិទ្ធិរបស់អ្នក ។
តើក្រុមសហគមន៏មូលដ្ឋាន ចាត់វិធានការទប់ទល់នឹង គំរោងដែលស្នើឡើងនៅក្នុង ប្រទេសរបស់អ្នកដែរឬទេ?
ពិនិត្យមើលថាតើ អង្គការនៅក្នុងតំបន់របស់អ្នក មានពតិមានច្រើនស្តីពី ទីកន្លែងដែលត្រូវស្វែងរកជំនួយ សំរាប់ដំណើរការ FPIC ។

## ឧបសម្ព័ន្ធ ទី ១:

## បណ្ដាប្រទេសដែល បានបង្ហាញការគាំទ្រ ចំពោះសេចក្ដីថ្លែងការណ៍របស់ អង្គការសហប្រជាជាតិ ស្ដីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP)

UNDRIP គឺជាសេចក្ដីថ្លែងការណ៍របស់ អង្គការសហប្រជាជាតិ ស្ដីពីសិទ្ធិជនជាតិដើមភាគតិច។ នៅក្នុងច្បាប់អន្តរជាតិនេះមានន័យថា វាមិនមែនជាកាតព្វកិច្ច ជាផ្លូវច្បាប់ នៅលើប្រទេសជាច្រើននោះទេ ។ វានៅតែមានសារៈសំខាន់ ដោយវាបានបង្កើតជាបទដ្ឋាន ដែលទទួលស្គាល់ និង យល់ព្រមដោយសហគមន៍ និង រដ្ឋាភិបាលអន្តរជាតិ ។
បើសិនជាប្រទេសរបស់អ្នកគាំទ្រ សេចក្ដីថ្លែងការណ៍នោះ វាគួរតែត្រូវបានប្ដេជ្ញាចិត្ត ដើម្បីធ្វើការការពារសិទ្ធិទាំងនោះ ។ តារាងលំហូរនៅក្នុងទំព័រទី ១០ បង្ហាញពីសារៈសំខាន់នៃ UNDRIP ក្នុងការ ការពារសិទ្ធិជនជាតិដើមភាគតិច និង ចូលរួមវិភាគទាន ការអភិវឌ្ឍន៍ប្រកបដោយ និរន្តរភាព ។

## ប្រទេសចំនួន ១៤៧ គាំទ្រ UNDRIP

អាហ្គានីស្ថាន អាល់បានី អាល់សេរី អង់ដូរ៉ា អង់ហ្គោឡា អង់ទីហ្គា បាប៊ូដា អាហ្សង់ទីន អាមេនី អូស្ត្រាលី អូទ្រីស ប៉ាហាម៉ា បារ៉ែន បារបាដូស បេឡារ៉ូស បែលស៊ីក បែលី បេនីន បូឡាវី បូសនៀ ហេសេហ្គោនីណា ប៊្រុយណេ ដារ៉ូសាឡឹម ប៊ុលហ្គារី ប៊ូគីណា ហ្វាសូ កម្ពុជា កាំម៉ារូន កាប់វែត សាធារណៈរដ្ឋ អាហ្វ្រិកកណ្ដាល ឆាល ចិន កូឡុមប៊ី កូម្មរូស កុងហ្គោ កូស្ដារីកា ក្រូអាត គុយបា ស៊ីព្រូស សាធារណៈរដ្ឋ ឆេក សាធារណៈរដ្ឋ ប្រជាមានិតប្រជាធិបតេយ្យ កូរ៉េ សាធារណៈរដ្ឋប្រជាធិបតេយ្យ កុងហ្គោ ដាណឺម៉ាក ជីប៊ូទី ដូមីនិក សាធារណៈរដ្ឋ ដូមីនីក អេក្វាឌ័រ អេហ្ស៊ីប អែលសាវ៉ាឌ័រ អេស្តូនី ហ្វាំងឡង់ បារាំង ហ្គាបុង អាល្លឺម៉ង់ ហ្គាណា ក្រិក កាតេមាឡា គីណេ គូយ៉ាណា ហៃទី ហុងឌុយរ៉ាស់ ហុងគ្រី អៃឡិន ឥណ្ឌា ឥណ្ឌូណេស៊ី អៀរង់ (សាធារណៈរដ្ឋ អ៊ីស្លាម) អៀរ៉ាក់ អៀកឡង់ អ៊ីតាលី ចាម៉ៃកា ជប៉ុន កាសាស្ថាន គុយវ៉ែត សាធារណៈរដ្ឋ ប្រជាធិបតេយ្យប្រជាមានិត ឡាវ ឡាត់វីយ៉ា លីបង់ ឡេសូតូ លីបេរី លីប៊ី អារាប់ ចាម៉ាហ៊ីរីយ៉ា លិចេស្ដង់ លីទូអានី ឡុចសាំបួ ម៉ាដាហ្គាសស្ការ ម៉ាឡាវី ម៉ាឡេស៊ី ម៉ាឌីវ ម៉ាលី ម៉ាលតា ម៉ូរីទូស ម៉ិកស៊ិកូ មីក្រូណេស៊ី (សហពន្ធ័រដ្ឋ) មូដូវ៉ា ម៉ូណាកូ ម៉ុងហ្គោលី ម៉ូសាប៊ិក មីយ៉ាន់ម៉ា ណាមីប៊ី នេប៉ាល់ ហូឡង់ នីការ៉ាហ្គ័រ នីសេរី ន័រវេ អូម៉ាន់ ប៉ាគីស្ថាន ប៉ាណាម៉ា ប៉ារ៉ាហ្គាយ ប៉េរូ ហ្វីលីពីន ប៉ូឡូញ ព័រទុយហ្កាល កាតា សាធារណៈរដ្ឋ កូរេ សង់លូកា សង់វីសង់ និង សង់ហ្គ្រ្រង់ណាឌីន សាម៉ូ សង់ម៉ូរីណូ អារាប់ប៊ី សាវឌិត សេនេហ្កាល សែប៊ី សេរ៉ាលីអូន សាំងហ្គាពួ ស្លូវ៉ាគី ស្លូវេនី អាហ្វ្រិកខាងត្បូង អេស្ប៉ាញ ស្រីឡាំងកា ស៊ូដង់ ស៊ូរីណាម ស្វីស សាធារណៈរដ្ឋ ស៊េរី អារ៉ាប់ ថៃ អឌិត សាធារណៈរដ្ឋ យូហ្គោស្លាវី មេសេដូនី ទីម័រខាងកើត ទ្រីនីដា និង តូបាហ្គោ ទុយនេស៊ី ទួគី អារ៉ាប់រួម អារ៉ាប់ អេម៉ារេត ចក្រភពអង់គ្លេស និង អៀឡង់ខាងជើង សាធារណៈរដ្ឋ សហពន្ធ័ តង់សានី អ៊ុយរ៉ាហ្គាយ វេនេស៊ូអេឡា (សាធារណៈរដ្ឋ បូលីវ៉ារៀ), វៀតណាម, យេម៉ែន, ហ្សាមប៊ី និង ហ្ស៊ីមបាវេ ។

ប្រភព: http://www.un.org/esa/socdev/unpfii/en/declaration.html



ស្វែងរកតើអ្នកណាកំពុងតែបង្កើតគំរោង ផែនការ



ស្នើសុំពត៌មានពីអ្នកអភិវឌ្ឍន៍គំរោង



ធ្វើការពិភាក្សានៅក្នុងសហគមន៍របស់អ្នក



ការចចាររបស់សហគមន៍ ជាមួយអ្នកអភិវឌ្ឍន៍គំរោង



ស្វែងរកការផ្ដល់យោបល់ដោយឯករាជ្យ



ធ្វើការសំរេចចិត្តជាសហគមន៍



ធ្វើការច្រាស្រយ័ទាក់ទងជាប្រចាំជាមួយអ្នកអភិវឌ្ឍន៍គំរោង

## ការប្រឈមផ្សេងៗ

ការទាមទារសិទ្ធិ អំពី សេរីភាព ការទទួលបានពត៌មានជាមុន និង ការយល់ព្រម រមែងតែជាកិច្ចការ ជួបការប្រឈមមុខមួយ ។ FPIC ជាដំណើរការ និងការចរចារជាបន្តបន្ទាប់ អាចប្រើរយៈពេល ជាច្រើន ឆ្នាំ ។ សហគមន៏ដែលទទួលរងឥទ្ធិពលអាចមានតំរូវការក្នុងការចូលរួមរបស់គេ ក្នុងការចចារ ឬ នៅក្នុងករណី សហគមន៏ជនជាតិដើមភាគតិចដែលសិទ្ធិរបស់គេចំពោះ FPIC ត្រូវបានគោរព ។ ជារឿយៗ សិទ្ធិនេះ មិនត្រូវបានទទួលស្គាល់ជាស្វ័យប្រវត្តិឡើយ ។ ក្រុមហ៊ុនរួមទាំងរដ្ឋាភិបាល និង អ្នកផ្តល់មូលនិធិខ្លះ បានធ្វើអោយមានភាពជឿនលឿនចំពោះ ការគោរពសិទ្ធិទាំងនេះហើយមានគោលនយោបាយ និង ការប្តេជ្ញាចិត្ត ដែលគេអាចអនុវត្តនៅពេលកំពុងបង្កើតគំរោង ។ ប៉ុន្តែចំពោះ អ្នកអភិវឌ្ឍន៏ជាច្រើន គឺ FPIC នៅតែជាអ្វីមួយ ដែលគេមិន គោរព អនុវត្ត ឬយល់ដឹងអោយបាន ពេញលេញ ។

វាក៏អាចជាច្បាប់ជាតិនៅក្នុងប្រទេសមួយផងដែរដែលផ្លាស់ប្តូរវិធីអនុវត្ត FPIC អាចត្រូវបានទាមទារ ។ វាមានសារៈសំខាន់ណាស់ ចំពោះ សហគមន៏ដែលទទួលរងឥទ្ធិពលដោយគំរោងក្នុងការទទួល យោបល់ ពីច្បាប់មូលដ្ឋាន នៃ ប្រទេសរបស់គេ ។

## តើនរណាមានសិទ្ធិ ទទួលបានសេរីភាព ការទទួលបានពត៌មានជាមុន និង ការយល់ព្រម?

FPIC ជាសិទ្ធិពិសេសចំពោះ ជនជាតិដើមភាគតិច ដោយមានការទទួលស្គាល់នៅក្នុង សេចក្តីប្រកាស អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP) ។

អុកស្វាម អូស្ត្រាលី មានទស្សនៈថា រាល់សហគមន៏ដែលទទួលរង ឥទ្ធិពលដោយគំរោង មានសិទ្ធិក្នុងការពិគ្រោះយោបល់ និង ចរចារ នៅក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្ត ដែលមានឥទ្ធិពលមកលើពួកគេ ។ ប្រជាជន ដែលទទួលរងឥទ្ធិពលដោយគំរោង ដែលមិនមែនជាជនជាតិដើមភាគតិច មានសិទ្ធិក្នុងការពិគ្រោះយោបល់ និង ចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្តនៅក្នុងវិធីដែលមានលក្ខណៈស្របទៅនឹងគោលការណ៏ដែលមាននៅក្នុងសិទ្ធិចំពោះ FPIC ។

ចំពោះគោលបំណងនៃគោលការណ៏នេះ សហគមន៏ដែលទទួលរងឥទ្ធិពល ដោយ គំរោងទាំងអស់ ត្រូវបាន បញ្ចូល ដោយមិនគិត ដល់ សហគមន៏ ជនជាតិដើមភាគតិច ឬ មិនមែន ជាជាតិដើមភាគតិច ។ នេះផ្អែក ទៅលើការយល់ដឹងដែល សិទ្ធិរបស់ សហគមន៏ ទាំងអស់មិនអាចត្រូវបានពិចារណាដូចគ្នាទៅនឹង សិទ្ធិ ជនជាតិដើមភាគតិច ដោយ មិនគិតពីការយល់ព្រម ។ ទោះជាយ៉ាងណាក៏ដោយ សហគមន៏ដែល ទទួល រងឥទ្ធិពលដោយគំរោងទាំងអស់ត្រូវតែអាចចូលរួមក្នុង ការចរចារនិងការសំរេចចិត្ត ប្រកបដោយ ប្រសិទ្ធិភាព និង នៅពេលដែល សហគមន៏មិនមែន ជនជាតិដើម ភាគតិច និយាយ ថា ទេ ទៅដល់គំរោងមួយ នេះគួរតែត្រូវបានអោយមានតម្លាភាព ។

## បណ្តាអង្គការ

### សហប្រជាជាតិ

- ការទំនាក់ទំនងពិសេស សហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្ស និង សេរីភាពជាសារវ័ន្ត នៃជនជាតិដើមភាគតិច http://www2.ohchr.org/english/issues/indigenous/rapporteur/
- វេទិការអចិន្ត្រៃយ៏សហប្រជាជាតិ ស្តីពីបញ្ហាជនជាតិដើម http://www.un.org/esa/socdev/unpfii/

### អង្គការក្រៅរដ្ឋាភិបាល អន្តរជាតិ

- កតិកា ជនជាតិដើមភាគតិច អាស៊ីៈ www.aippnet.org
- ភ្នាក់ងារ កាតូលិក ដើម្បីអភិវឌ្ឍន៏អន្តរជាតិ : CAFOD www.cafod.org.uk
- កម្មវិធីប្រជាជន តំបន់ព្រៃៈ www.forestpeoples.org
- បណ្តាញទន្លេអន្តរជាតិៈ www.irn.org;
- អុកស្វាម អាមេរិកៈ www.oxfamamerica.org
- អុកស្វាម អូស្ត្រាលីៈ www.oxfam.org.au

### អង្គការនៅក្នុងតំបន់របស់អ្នក

- អង្គការសហគមន៏មូលដ្ឋានរបស់អ្នក និង NGOs នៅក្នុងមូលដ្ឋានផ្សេងទៀត
- វេទិការអង្គការមិនមែនរដ្ឋាភិបាល ឬក្រុមអង្គការនៅក្រោមឆត្រ័តែមួយ នៅក្នុងប្រទេសរបស់អ្នក
- សេវាផ្នែកច្បាប់ សហគមន៏មូលដ្ឋានរបស់អ្នក
- រដ្ឋអំណាចមូលដ្ឋាន របស់អ្នក ដូចជា ភ្នាក់ងារការពារបរិស្ថាន ឬ នាយកដ្ឋានបរិស្ថាន ឬ ធនធានធម្មជាតិ

## តើយើងអាចទទួលការគាំទ្រ និង ពត៌មានកាន់តែច្រើន នៅទីណា? តើអ្នកណាទៀត កំពុងធ្វើការនៅលើបញ្ហា ធនធានធម្មជាតិ?

តើអ្នកអាចធ្វើអ្វី បើសិនជារដ្ឋាភិបាល ឬអ្នកអភិវឌ្ឍន៏គំរោង មិនអើពើដល់អ្នក ? ទោះជាអ្នកព្យាយាមដើរតាមជំហ៊ានទាំងនេះ អ្នកអភិវឌ្ឍន៏គំរោងអាច មិនអើពើអ្នក ហើយបន្តគំរោងរបស់គេ ។ បន្ទាប់មកអ្នកអាច សំរេចបង្កើតយុទ្ធសាស្រ្តតស៊ូមតិ ដែលស្របទៅនឹងកាលៈទេសៈ និង ផលប្រយោជន៏របស់សហគមន៏អ្នក។ ទាំងនេះអាចជាការធ្វើលិខិតតវ៉ា ការតស៊ូដោយសន្តិវិធី និង ការបង្កើនការយល់ដឹងតាមរយៈ សារពត៌មាន និង អង្គការ NGOs ជាតិ និង អន្តរជាតិ ។NGOs បានបង្កើតឯកសារណែនាំអំពីការតស៊ូមតិសំខាន់ៗ ។

### ធនធានចំបងៗ

- សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិ ជនជាតិដើមភាគតិច (UNDRIP)
  http://www.un.org/esa/socdev/unpfii/en/declaration.html
- ពត៌មានបានផ្តល់ជាមុន និងសេរីភាពក្នុងការព្រមព្រៀងៈ តួនាទីរបស់ក្រុមហ៊ុនរ៉ែ **អុកស្វាម** អូស្ត្រាលី ២០០៧
  http://www.oxfam.org.au/campaigns/mining/docs/FPIC_statement.pdf
- ការបំបែកដីៈ ការចូលរួមរបស់សហគមន៏ នៅក្នុងគំរោង និស្សរណកម្ម និង ហេដ្ឋារចនាសម្ពន្ធ័ វិទ្យាស្ថានធនធានពិភពលោក, ២០០៩
  http://www.wri.org/publication/breaking-ground-engaging-communities
- សេរីភាព និង សមភាពចំពោះការគោរពសិទ្ធិមនុស្ស នៃជនជាតិដើមភាគតិច របស់ប្រទេសអូស្ត្រាលីៈ មគ្គុទេសក៏សំរាប់ការតស៊ូមតិ សហគមន៏ អុកស្វាម អូស្ត្រាលី និង កម្មវិធីបណ្តុះបណ្តាល ការទូត, ២០០៩
  http://www.dtp.unsw.edu.au/documents/FreeandEqual_FALR_002.pdf
- ទំនប់ ទន្លេ និង សិទ្ធិៈ មគ្គុទេសក៏ សកម្មភាពសំរាប់សហគមន៏ដែលទទួលរង ផលប៉ះពាល់ដោយ ទំនប់ បណ្តាញទន្លេអន្តរជាតិ ២០០៦ ( អាចរកបានពីគេហទំព័រមាន ១០ ភាសា)
  http://www.internationalrivers.org/en/node/579/
- អង្គការលើកលែងទោសអន្តរជាតិៈ សៀវភៅ ការរៀបចំយុទ្ធនាការ ឆ្នាំ ២០០៧
  www.amnesty.org/en/library/info/ACT10/002/1997
- ការណែនាំ និង ឧបករណ៏តស៊ូមតិ របស់អង្គការ Care: ការលើកកំពស់ ការផ្លាស់ប្តូរគោលនយោបាយ ឆ្នាំ ២០០១
  http://www.care.org/getinvolved/advocacy/tools/english_00.pdf
- ការតស៊ូមតិ ដើម្បីយុត្តិធមិសង្គមៈ សកម្មភាពសកល និង មគ្គុទេសការឆ្លុះបញ្ចាំង ឆ្នាំ ២០០១
  www.oxfamamerica.org/publications/advocacy-for-social-justice



## មាតិកា


បុព្វកថា.................................................................1

ពាក្យជំនួយសំខាន់ៗ.........................................................6

ការបង្កើតរូបភាពៈ ហេតុអ្វីមានគោលការណ៏នេះ និង នៅពេលនេះ?..........................8

ការយល់ដឹងពី FPIC : ឯកសារណែនាំ អំពី សេរីភាព ការទទួលបានពត៏មានជាមុន និង ការយល់ព្រម....9

តើ FPIC មកពីណា? តើវាប្រើប្រាស់សំរាប់អ្នកណា?....................................10

ជំហ៊ានអនុវត្តៈ របៀបប្រើប្រាស់ FPIC សំរាប់ការពារសិទ្ធិរបស់អ្នក.............................11

តើអ្នកអាចទទួលការគាំទ្រ និង ពត៏មានកាន់តែច្រើន មកពីណា?

តើអ្នកណាទៀតដែលកំពុងធ្វើការទៅលើបញ្ហា ធនធានធម្មជាតិ?.............................28

ឧបសម្ពន្ធ័ ១: ប្រទេសដែលបានបង្ហាញការគាំទ្រ

ចំពោះ សេចក្តីប្រកាស អង្គការសហប្រជាជាតិ

ស្តីពីសិទ្ធជនជាតិដើមភាគតិច (UNDRIP)..............................................30

ឧបសម្ពន្ធ័ ២: ទ្រង់ទ្រាយការងារ សំរាប់ស្រាវជ្រាវ ច្បាប់មូលដ្ឋាន ស្តីពី FPIC..................31

ឧបសម្ពន្ធ័ ៣: វដ្តគំរោង...................................................32

**ផលប្រយោជន៍:** អ្វីដែលល្អ ដែលបានកើតឡើងពីគំរោងសំរាប់សហគមន៏របស់អ្នកវាគួរតែជាការចរចារ រវាង សហគមន៏ និង អ្នកអភិវឌ្ឍន៏គំរោង ឬ រដ្ឋាភិបាល ។

**ការបែងចែកផលប្រយោជន៍:** វិធីដែលធានា ដល់ ផលប្រយោជន៏គំរោងត្រូវបានបែងចែករវាង សហគមន៏ ដែលទទួលរងផលប៉ះពាល់ ។

**ការយល់ព្រម:** ផ្តល់ ឬ បដិសេធន៏ ការព្រមព្រៀងរបស់អ្នកចំពោះគំរោង មួយ ដែលបណ្តាលមកពីអ្នក អភិវឌ្ឍន៏គំរោង ។

**ពិគ្រោះយោបល់:** នៅពេល អ្នកអភិវឌ្ឍន៏គំរោង និង សហគមន៏បែងចែកពត៌មានគ្នា និង ពិភាក្សា អំពីគំរោង ផែនការ ការពិគ្រោះយោបល់ ខុសពីការយល់ព្រម ។

**សិទ្ធិសមូហភាព:** សិទ្ធិរបស់ក្រុមមនុស្ស មួយក្រុម ដូចជាសហគមន៏មួយ ។ វាមិនមែនជាសិទ្ធិរបស់បុគ្គល ម្នាក់ៗឡើយ ។

**សេចក្តីថ្លែងការណ៍:** នៅក្នុងប្រពន្ធ័អង្គការសហប្រជាជាតិ (UN) វាជាសេចក្តីប្រកាស របស់បណ្តាប្រទេស ក្នុងពិភពលោក ។ វាមិនមែនជាការកំនត់តាមផ្លូវច្បាប់នោះទេ ។ វាបង្កើតជាគោលការណ៏ដែល រដ្ឋាភិបាលព្រមព្រៀងធ្វើការទៅលើ ។ វាអាចក្លាយជាការបញ្ចូលគ្នា បើសិនជាមានការ បញ្ចូល ច្បាប់ជាតិផ្សេងៗ ។

**ដំណើរការធ្វើសេចក្តីសំរេចចិត្ត:** វិធីដែលសហគមន៏របស់អ្នក ជ្រើសរើសដើម្បីសំរេច ថាតើ ត្រូវផ្តល់ ឬ បដិសេធន៏ ការយល់ព្រម របស់អ្នកចំពោះគំរោង ។

**ការបំលាស់ទីតាំង:** ការបាត់បង់របស់ប្រជាជន ក្នុងការទទួលបាន ផ្ទះសំបែង និង ដីធ្លី ។

# ពាក្យសំខាន់ៗ



## ចំនុចសំខាន់ទី ៦

ស្នើដល់ភ្នាក់ងារឯករាជ្យ អោយជួយជាមួយនឹង ការត្រួតពិនិត្យ អាចជួយបញ្ចុះបញ្ចូល អ្នកអភិវឌ្ឍន៏គំរោង ដែលពាក់ពន្ធ័ពីឥទ្ធិពលគំរោង និង សហគមន៏ ទៅជាផ្លូវការ ។

## ចំនុចសំខាន់ទី ៧

វាជាការសំខាន់ ដើម្បីយល់ដឹង និង ចរចារយុទ្ធសាស្រ្ត ដកចេញជាមួយអ្នកអភិវឌ្ឍន៏ គំរោងមុននឹងគំរោងបញ្ចប់ ។ នេះអាចរួមបញ្ចូល ការទទួលបានទឹកស្អាត ការថែរក្សា មធ្យោបាយផ្សេងៗ និង ការបណ្តុះបណ្តាលឡើងវិញ ដើម្បីបង្កើនឱកាសការងារ ។

តំណាងសហគមន៏ ក៏ត្រូវការធ្វើការត្រួតពិនិត្យ ការអភិវឌ្ឍន៏គំរោងដែរ បើសិនជាគំរោងនៅបន្ត ។ វាមានសារៈសំខាន់ចំពោះសហគមន៏ ដើម្បីពិនិត្យមើល ថាតើក្រុមហ៊ុន/រដ្ឋាភិបាល មានការឆ្លើយតបទៅនឹង ការប្តេជ្ញាចិត្តរបស់គេដែរឬទេ ។ វិធីមួយដើម្បីធ្វើការងារនេះ គឺធ្វើការចរចារលទ្ធផល ឬ លក្ខខ័ណ្ឌជាក់លាក់ផ្សេងៗ របស់គំរោង ។ ទាំងនេះគួរត្រូវបាន សរសេរទុក និង កំណត់ពេលដែលបានឯកភាព ។
អ្នកអភិវឌ្ឍន៏គំរោង អាចធ្វើការផ្លាស់ប្តូរនៅក្នុង អំឡុងពេលនៃដំណើរការគំរោង ។ អ្នកអភិវឌ្ឍន៏គំរោងថ្មី លើកឡើងនូវការប្តេជ្ញាចិត្ត ដែលធ្វើឡើងដោយ អ្នកអភិវឌ្ឍន៏មុន ទោះជាយ៉ាងណាក៏ដោយ អ្នកអាចចង់ស្វែងរកការផ្តល់ យោបល់ឯករាជ្យ ដើម្បីយល់ដឹង បើសិនជាអ្នកអភិវឌ្ឍន៏គំរោងថ្មី ត្រូវបានបន្តដោយកិច្ចព្រមព្រៀងមុន។ នេះជាមូលហេតុមួយ ដែលវាមាន សារៈសំខាន់ អោយមានការកត់ត្រាជាលាយលក្ខ័អក្សរ នូវការសំរេចចិត្តរបស់សហគមន៏អ្នក អំពីគំរោង និង ផលប្រយោជន៏ ដែលអ្នកបានចរចារ ។ អ្នកអាចព្យាយាមចរចារ ដើម្បីបង្កើនផលប្រយោជន៏ សំរាប់សហមន៏អ្នក ជាមួយអ្នកអភិវឌ្ឍន៏ថ្មី ។ សហគមន៏របស់អ្នក ក៏អាចចង់បង្កើតវេទិការ អ្នកអភិវឌ្ឍន៏គំរោង និង សហគមន៏ជាប្រចាំ ដើម្បីអោយមានការប្រាស្រ័យទាក់ទងគ្នា ជាបន្តបន្ទាប់ និង បានទៀងទាត់ ។ វេទិកានេះក៏អាចត្រូវបាន ប្រើប្រាស់ដោះស្រាយកង្វល់ និង សារទុក្ខ ដែលសហគមន៏អាចមាន ជាមួយនឹងការប្រតិបត្តិគំរោង បើសិនជាគំរោងបន្ត ។

**ជំហ៊ានដែលបានបង្ហាញខាងលើ ត្រូវបានរៀបចំឡើងដើម្បីជួយ សហគមន៍អ្នក ទាមទារសិទ្ធិរបស់អ្នក ចំពោះពត៌មានបានផ្តល់ជាមុន និងសេរីភាពក្នុងការ ព្រមព្រៀង សិទ្ធិរបស់អ្នកក្នុងការពិគ្រោះយោបល់ និង សិទ្ធិរបស់អ្នកក្នុងការចរចារ នៅក្នុង ដំណើរការធ្វើសេចក្តីសំរេចចិត្ត ដែលមានឥទ្ធិពលលើអ្នក ។**



## ជំហ៊ានទី ៧:

### ការប្រាស្រ័យទាក់ទងជាបន្តបន្ទាប់ ជាមួយអ្នកអភិវឌ្ឍន៍គំរោង

ពតិមានបានផ្តល់ជាមុននិងការព្រមព្រៀងដោយមានសេរីភាព គឺជាដំណើរការជាបន្តបន្ទាប់ ។ គំរោងអភិវឌ្ឍន៏ខ្នាតធំ ចំណាយពេលជាច្រើនឆ្នាំ ក្នុងការធ្វើផែនការ និង បន្ទាប់មកចាប់ផ្តើមនិងបន្ទាប់មកអាច មានឥទ្ធិពលលើសហគមន៏របស់អ្នកជាច្រើនឆ្នាំ ឬរហូតដល់ច្រើនជំនាន់ ។ អ្នកអភិវឌ្ឍន៏គំរោងគួរតែធានា ដល់សហគមន៏របស់អ្នកអោយ ត្រូវបានផ្តល់ពតិមាន ជាទៀងទាត់ អំពីភាពរីកចំរើនរបស់គំរោង ។ អ្នកអាចត្រូវបានផ្តល់ឱកាស ដើម្បីសួរសំនួរ និងលើកឡើងនូវកង្វល់ ។ សិទ្ធិសហគមន៏របស់អ្នកចំពោះ FPIC ត្រូវតែត្រូវបានគោរព នៅក្នុងដំណើរការទាំងមូល ។

នៅក្នុងឧបសម្ព័ន្ធទី ៣ ទំព័រទី ៣២ បង្ហាញពីដំណាក់កាលទូទៅនៃគំរោងធំមួយ ។ នេះរួមមាន ការលើកឡើងនូវសារៈសំខាន់នៃការយល់ដឹង ពីសកម្មភាពផ្សេងៗ ដែលអាចកើតមានឡើងនៅ ដំណាក់កាលនិមួយៗនៃគំរោង និង អ្វីដែលអ្នកអភិវឌ្ឍន៏គំរោងគួរធ្វើ ដើម្បីអោយសហគមន៏ ចូលរួមនៅក្នុងដំណាក់កាលនិមួយៗ ។

**គួរចងចាំ:** គួរតែមិនមែន ជាដំណើរការ តែម្តងចប់នោះទេ វាជាដំណើរការជាបន្តបន្ទាប់ ។ នេះ មានន័យថា ការពិភាក្សាជាទៀងទាត់ និង ការព្រមព្រៀង រវាងអ្នកអភិវឌ្ឍន៏គំរោង និង សហគមន៏ ដែលទទួលរងឥទ្ធិពល គឺជាការអនុវត្តល្អ ។ បើសិនជានិយាយយល់ព្រម ឬ បដិសេធន៏ ចំពោះគំរោងមួយ តំណាងសហគមន៏អាចបន្ត អាចធ្វើការចរចារក្នុងនាមសហគមន៏របស់គេផ្ទាល់ ។ គេត្រូវតែធានាថា សហគមន៏ទាំងមូល ត្រូវបានផ្តល់ពតិមានទាំងអស់គ្នា ។

**ការបំលាស់ទីតាំងជាលក្ខណៈសេដ្ឋកិច្ច:** ការបាត់បង់ ការទទួលបានចំណូល ឬការចិញ្ចឹមជីវិត ដោយមកពីការបាត់បង់ការទទួលបានដីធ្លី ។

**ការប្រមូលផលដោយអ្នកមាន:** ភាពជាម្ចាស់ នៃការចរចារ ផលប្រយោជន៏ ជាមួយនឹង អ្នកអភិវឌ្ឍន៏គំរោង ដោយអ្នកមាន ឬ បុគ្គលមានឥទ្ធិពលខ្លះ សំរាប់ការទទួលបាន ជាលក្ខណៈបុគ្គលរបស់គេជាជាង ផលប្រយោជន៏ សហគមន៏ទាំងមូល ។

**ការប៉ាន់ស្មានពីឥទ្ធិពល សង្គម និង បរិស្ថាន:** ជាការសិក្សាដែលធ្វើឡើង មុននឹងគំរោងចាប់ផ្តើម ដើម្បីកំណត់ឥទ្ធិពលនៃគំរោងដែលស្នើឡើង ។ គោលបំណងរបស់វាគឺកំណត់ ឥទ្ធិពលអវិជ្ជមាន មកលើប្រជាជន និង បរិស្ថាន ។

**ឥទ្ធិពល:** ជាលទ្ធផលរបស់គំរោងអភិវឌ្ឍន៏ខ្នាតធំ ដែលមានឥទ្ធិពលអវិជ្ជមាន មកលើសហគមន៏ ។ ឧទាហរណ៏ ការបំពុល ទន្លេ ការកាប់ព្រៃឈើ ការផ្លាស់ទីតាំងភូមិ ។ នេះជាតំលៃនៃគំរោងដែលមាន បទពិសោធន៏ ដោយសហគមន៏ តែមិនមែនដោយអ្នកអភិវឌ្ឍន៏ គំរោង ឡើយ ។

**ការព្រមព្រៀងផលប្រយោជន៏ឥទ្ធិពល:** ជាការព្រមព្រៀងជាផ្លូវការ រវាងសហគមន៏ និង អ្នកអភិវឌ្ឍន៏គំរោង ដែលកត់ត្រាលក្ខខ័ណ្ឌ ដែលអ្នកអភិវឌ្ឍន៏គំរោងត្រូវឆ្លើយតប ។

**ច្បាប់អន្តរជាតិ:** ច្បាប់ដែល ដឹកនាំការទំនាក់ទំនង រវាងប្រទេសទាំងអស់ ។ នៅក្នុងផ្នែកសិទ្ធិមនុស្ស វាអាចពង្រីកវិធី ដែលក្នុងនោះ បណ្តាប្រទេសទាំងនោះ ចាត់ទុកជាបុគ្គល និង សហគមន៏ ។

**ធនធានធម្មជាតិ:** ចំពោះអ្នកអភិវឌ្ឍន៏គំរោង វាជាធនធាន នៅក្នុងបរិស្ថានដែល ដកហូតសំរាប់ផលប្រយោជន៏ សេដ្ឋកិច្ចដូចជា ឈើហ៊ុប ប្រេង និង ទឹក ។ សំរាប់សហគមន៏ វាជាធនធាន សំរាប់ការចិញ្ចឹមជីវិត ដូចជាទឹកសំរាប់ហូប ដីសំរាប់ធ្វើកសិកម្ម និង ការចិញ្ចឹមសត្វ ។

**ការចចារ:** ការពិភាក្សាលើកិច្ចព្រមព្រៀង ដែលអនុវត្តនៅក្នុងដំណើរការយុត្តិធមិមួយ ជាធម្មតារវាង អ្នកអភិវឌ្ឍន៏ និង សហគមន៏ដែលទទួលរងឥទ្ធិពល ។ នេះគួរតែមានតុល្យភាពនៃអំណាច ។ គំរោងមិនគួរបន្តទៅមុខឡើយ បើសិនជាការចរចារមិនទាន់បានបញ្ចប់ ។

**អង្គការក្រៅរដ្ឋាភិបាល (NGO):** អង្គការដែលមានឯករាជ្យភាពពីរដ្ឋាភិបាល ។ វាមិនមែនជាក្រុមហ៊ុនឡើយ ។ វារួមទាំងអង្គការ សាសនា (ដូចជាវិហាកាតូលិក) និង អង្គការសង្គមស៊ីវិល និង អង្គការសហគមន៏មូលដ្ឋានផ្សេងៗ ។

**អ្នកអភិវឌ្ឍន៏គំរោង:** ធនាគារ ក្រុមហ៊ុន ឬ រដ្ឋាភិបាល ដែលកំពុងចង់អភិវឌ្ឍន៏គំរោង ។ វារមែងតែមានភាគីផ្សេងៗចូលរួមក្នុងការអភិវឌ្ឍន៏គំរោង ។

**ការតាំងលំនៅថ្មី:** ការផ្លាស់ប្តូរទៅកន្លែងថ្មីដើម្បីរស់នៅ និងប្រកបការចិញ្ចឹមជីវិត ដើម្បីផ្តល់ផ្លូវសំរាប់ គំរោងអភិវឌ្ឍន៏ធំមួយ ។ ពេលខ្លះ ការប្តូរទីលំនៅត្រូវបានធ្វើឡើង ដោយរដ្ឋាភិបាលជាតិ ជំនួសដោយ អ្នកអភិវឌ្ឍន៏គំរោង ។

**ហានិភ័យ:** អាចមានរបួស ការបាត់បង់ ឬ គ្រោះថ្នាក់ ។ ហានិភ័យអាចមានបទពិសោធន៏ ដោយបុគ្គល ឬ សហគមន៏ទាំងមូល ។ អ្នកអភិវឌ្ឍន៏គំរោង អាចប្រទះ នឹង ហានិភ័យដែរ ឧទាហរណ៏ ខូចកេរ្តិ៍ឈ្មោះរបស់គេ បើសិនជាគេមានជំលោះ ឬទំនាស់ជាមួយប្រជាជនដែលទទួលរង ឥទ្ធិពលដោយសារគំរោង ។

## ការបង្កើតឡើងនូវមគ្គុទេសៈ
## ហេតុអ្វី មានមគ្គុទេសក៏នេះ ហើយនៅពេលនេះ?

គំរោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ និង ឧស្សាហកម្មពិភពលោក ត្រូវបាន និង កំពុងអភិវឌ្ឍន៏ នៅក្នុងជំហ៊ានយ៉ាងលឿន ។ គំរោងទាំងនោះ រមែងតែដឹកនាំដោយតំរូវការ ដែលកំពុងតែកើនឡើងជាអចិន្ត្រៃយ៏ ចំពោះធនធានធម្មជាតិ ។ វារួមមាន ការកាប់ព្រៃ យកឈើ ការជីកយករ៉ែ និង ប្រេង និង តំរូវការទន្លេ សំរាប់ថាមពលវារីអគ្គិសនី ។ វាអាចធ្វើអោយមានការផ្លាស់ប្តូរ យ៉ាងខ្លាំងដល់ ជីវិត មនុស្ស លក្ខណៈនៃការរស់នៅរបស់គេ និង បរិស្ថាននៅក្នុង និង នៅជុំវិញតំបន់គំរោង ។

បើសិនជាបានអភិវឌ្ឍន៏ ប្រកបដោយ និរន្តរភាព គំរោងទាំងនោះអាច និង គួតែមានផលប្រយោជន៏ ដល់ប្រជាជនមូលដ្ឋាន ។ គំរោងបែបនោះ គួជៀសវាងអោយមាន ឥទ្ធិពលជាលក្ខណៈអវិជ្ជមាន ដល់បរិស្ថាន និង សង្គម និង ធ្វើដោយមិនមានគ្រោះថ្នាក់ ។

ប៉ុន្តែវាជារឿយៗបំផុត គំរោងបែបនោះ ធ្វើអោយមានបញ្ហា និង លក្ខណៈអវិជ្ជមាន មានឥទ្ធិពល ជាប់ជាយូរអង្វែងរួមទាំង ចំពោះសិទ្ធិមនុស្សផងដែរ ។ មូលហេតុមួយក្នុងចំណោម មូលហេតុចំបងៗជាច្រើន ចំពោះបញ្ហានេះ គឺពួកគេរមែងតែ ធ្វើការអភិវឌ្ឍន៏ ដោយមិនបាន ពិចារណាពិតប្រាកដណាមួយ ចំពោះសិទ្ធិ ផលប្រយោជន៏ របស់ប្រជាជន ដែលទទួលរងឥទ្ធិពល ពីគំរោង និង បរិស្ថាន ។

មានរបៀបផ្សេងៗជាច្រើន ដែលគំរោងអភិវឌ្ឍន៏ខ្នាតធំ អាចមានឥទ្ធិពល មកលើសហគមន៏ ។ តារាងនេះបង្ហាញពីឥទ្ធិពល ជាសក្តានុពលរបស់គំរោងមួយអាចមាន:

| | |
|---|---|
| › មានការងារកាន់តែច្រើនសំរាប់ សមាជិក សហគមន៏ | › សំពាធក្នុងការរើចេញពីដីរបស់អ្នក |
| › ការបណ្តុះបណ្តាលជំនាញ | › ត្រូវបានបដិសេធន៏ ចំពោះការទទួលបាន និង ប្រើប្រាស់ដី សំរាប់ ផលិត កម្មស្បៀង ឬការអនុវត្តវប្បធម៌ |
| › ប្រពន្ធ័អនាមយ័ និង ទឹកកាន់តែប្រសើរ | › ខ្យល់ ឬ ទឹក របស់អ្នកនឹងត្រូវបាន ធ្វើអោយកខ្វក់ |
| › ធ្វើអោយប្រសើរឡើងនូវផលិតកម្មស្បៀង | › ត្រី សត្វ ឬរុក្ខជាតិ នៅក្នុងតំបន់របស់អ្នក មានការបាត់បង់ |
| › មានផលប្រយោជន៏ហិរញ្ញវត្ថុ | › បង្កើនអំពើហឹង្សា និង សំពាធសង្គម |
| › មាន ផ្ទះ សាលា និង មណ្ឌលសុខភាពថ្មីៗ | › ការងាររមែងតែ មិនទៀងទាត់ |
| | › កម្មករដែលមកនៅក្នុងតំបន់គំរោងរមែងតែបង្កើតហានិភ័យសុខភាព សំរាប់សហគមន៏ |

FPIC គឺជាសិទ្ធិសមូហភាពយ៉ាងសំខាន់មួយ ដែលអាចជួយគំរោង អោយកាន់តែមាននិរន្តរភាព ។ វាអាចត្រូវបានទាមទារដោយជនជាតិដើមភាគតិច ដែលគំរោងមាន ឥទ្ធិពលលើជីវិត ការរស់នៅ ឬជីវិធីរបស់គេ ។ ចំពោះសហគមន៏ដែលទទួលរងឥទ្ធិពល ដោយគំរោង ផ្សេងទៀត ការចូលរួមយ៉ាងពេញលេញ និង មានប្រសិទ្ធភាពរបស់ពួកគេ ក្នុងការចរចារទៅលើការ ធ្វើផែនការ និង ការអនុវត្តគំរោង ទាំងនោះត្រូវតែទទួលបានការធានា ។

ទោះជាច្បាប់ជាតិបានផ្តល់នូវការការពារយ៉ាងខ្សោយ ទៅដល់សិទ្ធិចំពោះ FPIC និង សិទ្ធិនៃការការពារប្រជាជនដែលទទួលរងឥទ្ធិពលដោយគំរោង ក្នុងការពិគ្រោះយោបល់ និង ការចូលរួម ក្នុងដំណើរ ការសំរេចចិត្ត ក៏ដោយក៏ច្បាប់នេះ អាច និង គួរតែត្រូវបានទទួលស្គាល់ដោយ អ្នកអភិវឌ្ឍន៏គំរោង ។

គោលការណ៏នេះមានបំណងជួយ សហគមន៏ ដែលទទួលរងឥទ្ធិពលពីគំរោង អោយយល់កាន់តែប្រសើរ ពីសិទ្ធិរបស់គេទាក់ទងទៅនឹង FPIC និង របៀបដែលវាដំណើរការ ។ វាមានបំណងផ្តល់អោយពួកគេនូវ ធនធាន និង ការគាំទ្រខ្លះក្នុងការ ការពារសិទ្ធរបស់ពួកគេ ដែលគំរោងមួយត្រូវបានស្នើរឡើង នៅតំបន់របស់គេ ។ វាជាឧបករណ៏ សំរាប់សហគមន៏ដើម្បីធ្វើអោយ អ្នកអភិវឌ្ឍន៏គំរោង និង រដ្ឋាភិបាលមានការទទួលខុសត្រូវខ្ពស់ ។

**អ្នកអភិវឌ្ឍន៍គំរោងខ្លះអាចព្យាយាម ទទួលការយល់ព្រមពីសហគមន៍ចំពោះគំរោង ដោយធ្វើអោយម្ចាស់ដី និង តំណាងរបស់គេផ្សេងទៀត ដឹកស្រវឹង និង បង្ខំអោយពួកគេចុះហត្ថលេខា លើកិច្ចព្រមព្រៀង ។ អ្នកអភិវឌ្ឍន៍គំរោងខ្លះអាចព្យាយាម ទទួលការយល់ព្រមពីសហគមន៍ចំពោះគំរោង ដោយបង្កើតដំណើរ ការធ្វើសេចក្តីសំរេចចិត្តដោយសហគមន៍ផ្ទាល់ ។ ដំណើរការនេះមិនបានរួមបញ្ចូល រចនាសម្ព័ន្ធធ្វើសេចក្តីសំរេចចិត្តប្រពៃណី ឬ តំណាងសហគមន៍ ដែលស្របច្បាប់ និងត្រូវបានរៀបចំដើម្បីទទួលបាន ការយល់ព្រមទោះជាដំណើរការនោះមានការក្លែងបន្លំក៏ដោយ ។**

**គួរចងចាំ:** អ្នកអភិវឌ្ឍន៏គំរោង មិនត្រូវដាក់សម្ពាធ គំរាមកំហែង ឬ បង្ខិតបង្ខំអ្នក នៅក្នុងវិធីណាមួយ ដើម្បីធ្វើការសំរេចចិត្ត ឬ ផ្តល់ការយល់ព្រមរបស់អ្នកចំពោះគំរោង ។

ឧទាហរណ៏ខ្លះនៃរបៀបដែលអ្នកអភិវឌ្ឍន៏គំរោង ពេលខ្លះធ្វើអោយដំណើរការមានការលំបាកដូចជា:

- មិនរួមបញ្ចូលសហគមន៏នៅក្នុង ដំណាក់កាលដំបូងនៃការប៉ាន់ប្រមាណឥទ្ធិពល
- បង្ខំអោយសហគមន៏ ចុះហត្ថលេខាលើកិច្ចព្រមព្រៀង នៅពេលដែលដឹងយ៉ាងច្បាស់ថា គេមិនយល់ពេញលេញពីឥទ្ធិពលនៃគំរោង
- មានការចរចារ ឬការពិភាក្សាជាមួយបុគ្គលខ្លះដែលមិនតំណាងអោយទស្សនៈសហគមន៏ ។



## ជំហ៊ានទី ៦:

### ធ្វើការសំរេចចិត្ត ក្នុងនាមជាសហគមន៍មួយ

សេរីភាពការទទួលបានពត៌មានជាមុន និង ការយល់ព្រម ជាសិទ្ធិសមូហភាព ។ ដូច្នេះ សហគមន៍របស់អ្នកត្រូវតែធ្វើការសំរេចចិត្តរួមគ្នា ដោយយោងទៅលើដំណើរការប្រពៃណីរបស់អ្នកផ្ទាល់ ។ បើសិនជាអ្នកសំរេច និយាយថាយល់ព្រម ចំពោះគំរោងមួយ អ្នកគួរតែបញ្ជាក់ថា កិច្ចព្រមព្រៀងដែល អ្នកធ្វើឡើងជាមួយ អ្នកអភិវឌ្ឍន៏គំរោង ត្រូវបានកត់ត្រាទុកជាលាយលក្ខ័អក្សរ ។ អ្នកអាចសរសេរវានៅក្នុងភាសារបស់សហគមន៏អ្នក ។ កិច្ចព្រមព្រៀងនេះ គួរតែជាកិច្ចព្រមព្រៀងប្រើជាផ្លូវច្បាប់ ។ នេះអាចជាដំណើរការ យ៉ាងពិបាក និង ការយល់ដឹងពីកិច្ចព្រមព្រៀងគំរោង ការសំរេចរបស់រដ្ឋាភិបាល និង ឯកសារច្បាប់ផ្សេងៗ មានភាពយ៉ាងស្មុគស្មាញ ។ មានការផ្តល់យោបល់ អោយស្វែងរកជំនួយ ពី អង្គការ មិនមែនរដ្ឋាភិបាល ឬ អ្នកណាម្នាក់ ដែលមានជំនាញទាក់ទង ដើម្បីជួយអ្នកបើសិនជា អ្នកមិនយល់ពី កិច្ចព្រមព្រៀង និង ឯកសារផ្សេងៗ ។ បើសិនជាសហគមន៏របស់អ្នក ផ្តល់ការយល់ព្រមចំពោះគំរោង សហគមន៏របស់អ្នកអាចជ្រើសរើស ដើម្បីចូលទៅក្នុងកិច្ចព្រមព្រៀងផលប្រយោជន៏ជាឥទ្ធិពល ( ឬដូចគ្នា ) ជាមួយអ្នកអភិវឌ្ឍន៏គំរោង ។ នេះជាកិច្ចព្រមព្រៀងផ្លូវច្បាប់ដែលកត់ត្រាកិច្ចព្រមព្រៀង ដែលឯកភាពរវាងសហគមន៏របស់អ្នក និង អ្នកអភិវឌ្ឍន៏គំរោង ។ វាកត់ត្រាពីលក្ខខណ្ឌ័ដែលអ្នកអភិវឌ្ឍន៏គំរោង ត្រូវតែឆ្លើយតប និង ពេលណាលក្ខខណ្ឌ័ទាំងនេះត្រូវបានអនុវត្ត និង ធ្វើការបែងចែក ។

**គួរចងចាំ:** បើសិនជាសហគមន៏របស់អ្នកជឿថាគំរោង នឹង មិនមានលក្ខណ:វិជ្ជមានសំរាប់សហគមន៏ទេ អ្នកអាចនិយាយបដិសេធន៏ ឬ អាចនិយាយថា អ្នកមិនផ្តល់ការយល់ព្រមចំពោះគំរោង ។ គំរោងអាចបន្តទៅបានបើជាការយល់ព្រមរបស់ជនជាតិដើមភាគតិច ត្រូវបានទទួលដោយ រដ្ឋាភិបាល និង អ្នកអភិវឌ្ឍន៏គំរោង ។ ចំពោះសហគមន៏ដែលទទួលរងឥទ្ធិពលដោយគំរោង ដែលមិនមែនជនជាតិភាគតិច នៅពេលដែលគេនិយាយថាទេ ចំពោះគំរោងនេះគួរតែមានការទទួលខុសត្រូវខ្ពស់ ។

## ការយល់ដឹងពី FPIC:
## សេរីភាព ការទទួលបានពត៏មានជាមុន និង ការយល់ព្រម

សេរីភាព ការទទួលបានពតិមានជាមុន និង ការយល់ព្រម (FPIC) គឺអំពីសហគមន៏ជនជាតិដើម មានសិទ្ធិពិសេស ដែលអ្នកផ្សេងទៀតគួរគោរព ។ វាជា " សិទ្ធិ សមូហភាព " ។ នេះមាននយ័ថា សហគមន៏របស់អ្នកទាំងមូលមានសិទ្ធិ យល់ព្រម ឬបដិសេធន៏អំពីសេរីភាព ការទទួលបានពតិមានជាមុន និង ការយល់ព្រម ។

ផ្នែកនិមួយៗនៃពាក្យនេះ មានអត្ថន័យសំខាន់ៗសំរាប់អ្នក និង សហគមន៏របស់អ្នក ។ ខាងក្រោមនេះជាការពន្យល់សាមញ្ញៗរបស់អត្ថន័យពាក្យនិមួយៗ:

- **មានសេរីភាព** ពីការប្រើកំលាំង ការបំភ័យ ការបោកបញ្ឆោត ការបង្ខិតបង្ខំ ឬ សំពាធ ដោយរដ្ឋាភិបាល ឬ ក្រុមហ៊ុនណាមួយ ។
- **ជាមុន** គឺមុននឹងរដ្ឋាភិបាលដាក់ដី សំរាប់ធ្វើការប្រើប្រាស់ជាក់លាក់ណាមួយ និង មុននឹងការសំរេចគំរោងជាក់លាក់ផ្សេងៗ ។ អ្នកត្រូវបានគេផ្តល់ពេលវេលាគ្រប់គ្រាន់ ដើម្បីធ្វើការពិចារណារាល់ពតិមានទាំងអស់ និង ធ្វើការសំរេចចិត្ត ។
- **បានផ្តល់ពត៏មាន** គឺអ្នកត្រូវបាន ផ្តល់ពតិមានដែលពាក់ពន្ធ័ទាំងអស់ ដើម្បីធ្វើការសំរេចចិត្ត របស់អ្នកអំពី ថាតើត្រូវយល់ព្រមលើគំរោង ឬ មិនយល់ព្រម ( មើល ទំព័រទី ១៦ និង ១៧ ពីបញ្ជីសំនួរ សំរាប់សួរអ្នកអភិវឌ្ឍន៏គំរោង) ។
  - ពតិមានទាំងអស់នេះ ក៏ត្រូវតែជាភាសាមួយ ដែលអ្នកអាចយល់យ៉ាងងាយ
  - អ្នកត្រូវតែទទួលបានពតិមានដែលឯករាជ្យ គឺ មិនត្រឹមតែពតិមានដែលបានមកពី អ្នកអភិវឌ្ឍន៏គំរោង ឬ រដ្ឋាភិបាលរបស់អ្នកឡើយ ។
  - អ្នកក៏អាចទទួលបាននូវអ្នកជំនាញ ស្តីពីបញ្ហាច្បាប់ និង បច្ចេកទេសផងដែរ បើសិនជា មានការស្នើឡើង ដើម្បីជួយក្នុងការធ្វើសេចក្តីសំរេចចិត្តរបស់អ្នក ។
- **ការយល់ព្រម** តំរូវថា អ្នកដែលចូលរួមនៅក្នុងគំរោង អនុញ្ញាតិអោយសហគមន៏ ជនជាតដើម និយាយថា យល់ព្រម ឬ មិនយល់ព្រម ចំពោះគំរោង ហើយនៅរាល់ដំណាក់កាលនិមួយៗនៃគំរោង ដោយអាស្រយ័ទៅនឹង ដំណើរការសំរេចចិត្ត នៃការជ្រើសរើសរបស់អ្នក ។ សិទ្ធិក្នុងការផ្តល់ឬលើកឡើង នូវការយល់ព្រម គឺជាភាពខុសគ្នា យ៉ាងសំខាន់បំផុត រវាងសិទ្ធិជនជាតិដើមភាគតិច និង ប្រជាជន ដែលទទួលរងផលប៉ះពាល់ដោយគំរោង ។

សំរាប់ប្រជាជនដែលមិនមែនជាជនជាតិដើមភាគតិច សិទ្ធិរបស់អ្នកនៅក្នុងការពិគ្រោះយោបល់ និង ចរចារនៅក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្ត ដែលមានឥទ្ធិពលមកលើអ្នក ក៏ត្រូវតែមានការណែនាំដោយគោលការណ៏នៃ FPICដែរ ។ ការពិគ្រោះយោបល់ និង ការចរចារគួរត្រូវបានធ្វើឡើង តែនៅពេលណាដែលអ្នកមិនត្រូវបានបង្ខំ ឬ ដាក់សំពាធអោយចូលរួមមុន នឹង ការសំរេចចិត្តត្រូវបានធ្វើឡើង និង ការយល់ព្រមត្រូវបានធ្វើឡើង នៅពេលដែលអ្នកត្រូវបានផ្តល់ពតិមានពេញលេញលើបញ្ហាដែលបានពិភាក្សា និង ចរចារ ។

ការពារសិទ្ធិសហគមន៏របស់អ្នក ដើម្បីចរចារក្នុងការសំរេចចិត្ត ដែលមានឥទ្ធិពលមកលើអ្នក ។ នេះ អាចមាននយ័ថា វាអាចជាដំណើរការធ្វើសេចក្តីសំរេចចិត្តជាលក្ខណ:ប្រពៃណី ។ សហគមន៏ខ្លះ ជ្រើសរើសតំណាងសហគមន៏ ដើម្បីធ្វើការចរចារជាមួយ អ្នកអភិវឌ្ឍន៏គំរោង ជំនួសអោយសហគមន៏របស់គេ ។

*ចំណាំ: ដើម្បីជួយអ្នកអោយយល់ FPIC អ្នកត្រូវចំណាយពេលអានមាត្រានិមួយៗរបស់សេចក្តីប្រកាសអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនជាតិដើមភាគតិច ។*

**សហគមន៍ត្រូវការការពារ ទប់ទល់នឹង អ្នកអភិវឌ្ឍន៍គំរោង ដែលអាចព្យាយាមបង្កើត ដំណើរការដែលមានការគាបសង្កត់របស់គេ នៅពេលដែលដំណើរការ ធ្វើសេចក្តីសំរេចចិត្តជាលក្ខណ:ប្រពៃណីមានរួចជាស្រេចហើយ។**

## តើ FPIC មកពីណា?
## តើវាអនុវត្តចំពោះអ្នកណា?

សេរីភាព ការទទួលបានពត៌មានជាមុន និង ការយល់ព្រម គឺជាសិទ្ធិដែលទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិ ។ វាមាន បញ្ចូលនៅក្នុងច្បាប់ជាតិ ក្នុងប្រទេសខ្លះ ដូចជា ហ្វីលីពីន និង រដ្ឋខ្លះនៃប្រទេសអូស្ត្រាលី (ទោះជាច្បាប់ អាចមានការខុសគ្នារវាង រដ្ឋ និងរដ្ឋ ខេត្ត និង ខេត្តក៏ដោយ) ។

FPIC ក៏ត្រូវបានទទួលស្គាល់ផងដែរថា ជាការអនុវត្តដែលល្អនៅក្នុងគំរោងអភិវឌ្ឍន៏ ។ វាអាចមានផលប្រយោជន៏ ចំពោះក្រុមហ៊ុនដែលកំពុងវិនិយោគក្នុងគំរោងអភិវឌ្ឍន៏ខ្នាតធំ ៗ ។ ជាឧទាហរណ៏ វាអាចកាត់បន្ថយហានិភ័យ នៃ ជំលោះរវាង សហគមន៏ និង ក្រុមហ៊ុន បើសិនជាសហគមន៏ ត្រូវបានចូលរួមយ៉ាងសកម្មនៅក្នុងការសំរេចចិត្តនៃគំរោង ពីដំបូង ។ រដ្ឋាភិបាល ក៏មានផលប្រយោជន៏ផងដែរ ពីការការពារសិទ្ធិរបស់ប្រជាជនរបស់គេនេះ ។

តារាងលំហូរខាងក្រោម ផ្តល់នូវលក្ខណៈទូទៅ សាមញ្ញៗ ពី FPIC មកពីទីកន្លែងណា និង ការអនុវត្តទៅលើអ្នកណា:




**កំណត់សំគាល់:** លិខិតស្តីពីសិទ្ធិអន្តរជាតិ – ការសំរុះសំរួលការប្រកាសសិទ្ធិមនុស្សជាសកល កតិកាសញ្ញា អន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ចសង្គម និង វប្បធម៌ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និង ស៊ីវិល និង អនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិទាំងអស់នេះមានការ ទាក់ទងសំរាប់អនុវត្តគោលការណ៏ FPIC សំរាប់ប្រជាជនដែលទទួលរងឥទ្ធិពលទាំងអស់ ។

**ទោះជាមានច្បាប់ជាតិ ការពារសិទ្ធិសហគមន៍របស់អ្នក ចំពោះ FPIC វាក៏អាច មានការខុសឆ្គងដែរ ។ អំពើពុករលួយ ការអនុវត្តន៍មិនបានល្អ ឬ គ្មានការអនុវត្តន៍ ឬ ខ្វះឯករាជ្យភាព នៅក្នុងទីភ្នាក់ងារ រដ្ឋាភិបាល ដែលទទួលខុសត្រូវចំពោះការធានា FPIC អោយកើតមានឡើង ដូចតម្រូវការនៅក្នុងច្បាប់ អាចបង្កើតជាបញ្ហាចំពោះ សហគមន៍ ដែលព្យាយាមទាមទារសិទ្ធិរបស់គេចំពោះ FPIC ។**



## ជំហានទី ៥:

### ស្វែងរកការពិគ្រោះយោបល់ឯករាជ្យ

ការចរចារជាមួយ អ្នកអភិវឌ្ឍន៏គំរោង អាចមានការលំបាក ។ អ្នកអភិវឌ្ឍន៏គំរោង ពេលខ្លះព្យាយាមបញ្ចៀសការចូលរួមរបស់សហគមន៏ ។ បញ្ហាដែលទាក់ទង មានភាពស្មុគស្មាញ ។ អ្នកមានសិទ្ធិរកការពិគ្រោះ ឯករាជ្យផ្នែកបច្ចេកទេស និង ច្បាប់ ដើម្បីជួយអ្នកអោយយល់ ពីឥទ្ធិពលនៃគំរោង ដែលស្នើឡើង ។ ឧទាហរណ៏ ក្រុមហ៊ុនផ្តល់ពតិមានដល់អ្នកថា គេនឹងប្រើប្រាស់ជាតិបារត ។ បើសិនជាអ្នកមិនដែលដឹងពីបារត ឬ មិនដឹងច្រើនពីវា អ្នកអាចស្នើសុំយោបល់ ពីអ្នកឯកទេសវិទ្យាសាស្រ្ត ។ សូមចងចាំថា ការសំរេចចិត្តរបស់អ្នក គួរតែជាការសំរេចចិត្តដែលមានការផ្តល់ពតិមាន ។ គោលការណ៏ ដែលនៅខាងក្រោមរបស់ FPIC គឺការយល់ព្រមដោយ ជនជាតិដើមភាគតិច ដែលគួរតែត្រូវបាន ផ្តល់ពតិមាន ពីការយល់ព្រម ។

ចំពោះសមាជិកសហគមន៏ដែល ទទួលរងការប៉ះពាល់ទាំងអស់ ការចូលរួមរបស់ពួកគេ នៅក្នុងការចរចារ និង ការប្រឹក្សា នៅក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្ត គួរតែផ្អែកលើ ការផ្តល់ពតិមានយ៉ាងពេញលេញ លើបញ្ហាដែល កំពុងត្រូវបានពិភាក្សា និង ចរចារ ។

វាជាការសំខាន់គឺ មិនត្រូវពឹងផ្អែកតែលើពតិមាន ដែលក្រុមហ៊ុនបានផ្តល់អោយអ្នកនោះទេ ។ អ្នកអភិវឌ្ឍន៏គំរោងអាចព្យាយាមធ្វើអោយគំរោងរបស់គេ មានការទាក់ទាញដល់ សហគមន៏ដែល ទទួលរងឥទ្ធិពល ដើម្បីទទួលបានការយល់ព្រម ។ ពតិមានពីប្រភពផ្សេងទៀត អាចធានាអោយអ្នកយល់ដឹងពេញលេញពី ឥទ្ធិពលរបស់គំរោង នៅក្នុងរយៈពេលខ្លី និង វែង ហើយសិទ្ធិអ្វីខ្លះដែលអាចមាន ចំពោះសហគមន៏របស់អ្នក ។

**គួរចងចាំ:** *វាជាការសំខាន់ណាស់ក្នុងការស្វែងរក ថាតើច្បាប់ជាតិ ប្រទេសរបស់អ្នក ការពារសិទ្ធិរបស់អ្នកចំពោះ FPIC ឬ ដំណើរការដូចគ្នានេះចំពោះ FPIC ដែរឬទេ ។ ការពិគ្រោះយោបល់ ឯករាជ្យ អាចជួយអ្នកជាមួយបញ្ហានេះ ។*

ចំពោះ ពតិមានជាច្រើនទៀត អំពីទីកន្លែងដែលអ្នក អាចរកការពិគ្រោះយោបល់ សូមមើលទំព័រទី ២៨ ។



# ជំហានអនុវត្តៈ

## របៀបប្រើប្រាស់ FPIC សំរាប់ការពារសិទ្ធិរបស់អ្នក



## ជំហានទី ១:

### ស្វែងរក ថាតើអ្នកណា កំពុងអភិវឌ្ឍន៍ គំរោងផែនការ

ដំបូង អ្នកត្រូវដឹងពីអ្នកណាកំពុងតែធ្វើផែនការគំរោង ដែលមានឥទ្ធិពលលើសហគមន៍របស់អ្នក ។ បន្ទាប់មកអ្នកនឹងដឹង តើអ្នកណា ជាមនុស្ស ដែលគួរតែត្រូវបានស្វែងរកការយល់ព្រមរបស់អ្នក ។ អ្នកអភិវឌ្ឍន៍ និង ធ្វើផែនការគំរោងអាចមាន:

- រដ្ឋាភិបាលរបស់អ្នក
- ក្រុមហ៊ុនឯកជន (ដូចជា ក្រុមហ៊ុន ជីករ៉ែ ឬ សំណង់)
- រដ្ឋាភិបាលរបស់ប្រទេសផ្សេងណាមួយ
- អាជ្ញាធរមូលដ្ឋាន (ដូចជា ភ្នាក់ងារការពារបរិស្ថាន ឬ នាយកដ្ឋាន បរិស្ថាន ឬ/និង ធនធានធម្មជាតិ )
- ធនាគារ ឬ ស្ថាបន័ ហិរញ្ញវត្ថុ អន្តរជាតិ (ដូចជា ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍ អាស៊ី ឬ ធនាគារអភិវឌ្ឍន៍ អាហ្វ្រិក)

ពេលខ្លះ វាអាចមានការលំបាកក្នុងការស្វែងរកពតិមានអំពីអ្នកអភិវឌ្ឍន៍គំរោង ។ គំរោងធំៗ រមែងតែត្រូវបានបង្កើតឡើង ជាមួយផលប្រយោជន៍ចំរុះនៃរដ្ឋាភិបាល និង ក្រុមហ៊ុន ។ បើសិនជាអ្នកមានបញ្ហា ក្នុងការស្វែងរកមនុស្សដែលសមស្រប ដើម្បីទទួលបានពតិមានពីគំរោង អ្នកអាចទទួលការជួយពីអង្គការផ្សេងៗ រួមមានអង្គការអន្តរជាតិ និង ក្នុងស្រុក។ អ្នកសារពតិមានរួមទាំង សារពតិមានអន្តរជាតិ និង ទស្សនាវដ្តី ឧស្សាហកម្ម (ឧទាហរណ៏ ទស្សនាវដ្តីរ៉ែ) អាចមានពតិមានស្តីពី គំរោងផែនការ ។ ពេលខ្លះ អ្នកអភិវឌ្ឍន៍គំរោងមិនមែននៅក្នុងប្រទេសរបស់អ្នកទេ ។ វាអាចមានការលំបាកក្នុងការទាក់ទងពួកគេ និងអ្នកអាចត្រូវការជំនួយពីអ្នកផ្សេង ។

**វាជាការសំខាន់ដែល សមាជិកសហគមន៍ របស់អ្នក ត្រូវបាន ចូលរួម នៅក្នុងការចរចារ ផលប្រយោជន៍ គឺមិនគ្រាន់តែ អ្នកដឹកនាំខ្លះ ឬ អ្នកមានអំណាច ដែលអាចមានការចាប់អារម្មណ៍នៅក្នុង បង្កើនផលប្រយោជន៍ បុគ្គលខ្លួនឯង អោយដល់អតិបរមា ពីផលប្រយោជន៍ សហគមន៍ទាំងមូល ។ សមាជិកសហគមន៍ អ្នកទាំងអស់គួរតែការពារទប់ទល់ នឹង ការចាប់យករបស់ អ្នកមានអំណាចរបស់សហគមន៍ និង ដំណើរ ការចរចារ របស់អ្នកអភិវឌ្ឍន៍ ។**

ឧទាហរណ៏ខ្លះ នៃផលប្រយោជន៏ ដែលអ្នកអាចចរចារ សំរាប់សហគមន៏របស់អ្នក រួមមាន:

- មានការងារកាន់តែច្រើនសំរាប់សមាជិកសហគមន៏
- ការបណ្តុះបណ្តាលជំនាញ និង ម្ធ្យោបាយបង្កើតការងារ
- សាលា និង មណ្ឌលសុខភាពថ្មី
- ការទទួលបាន និង ប្រើប្រាស់សិទ្ធិ ពិសេសចំពោះធនធានធម្មជាតិ នៅក្នុងតំបន់គំរោងសំរាប់សហគមន៏ ដែលទទួលរងផលប៉ះពាល់ ពីគំរោង
- ការព្រមព្រៀងជាមួយ អ្នកអភិវឌ្ឍន៏គំរោង ដើម្បីទុកដីការពារខ្លះ ឧទាហរណ៏ តំបន់សំរាប់តំលៃវប្បធម៌ពីគំរោង
- ការបែងចែកផលចំណេញពីគំរោង

#### ចំនុចសំខាន់ទី ៤

អ្នកអភិវឌ្ឍន៍គំរោង មិនគួរ បង្ខំអ្នកដើម្បី ចូលទៅក្នុងការចរចារ មុននឹងអ្នក មានភាពរួចរាល់ ក្នុងការ ចរចារ ។ អ្នកអភិវឌ្ឍន៍គំរោង ត្រូវអោយពេលវេលាអ្នកគ្រប់គ្រាន់ ដើម្បីពិចារណាលើពតិមាន សំរេច ពីរបៀប ដែល អ្នកចង់ចរចារជាមួយ អ្នកអភិវឌ្ឍន៍គំរោង ហើយចុងក្រោយ ធ្វើការសំរេចជាសហគមន៏ ។

#### ចំនុចសំខាន់ទី ៥

បើសិនជា ការសាងសង់បានចាប់ផ្តើម លើគំរោងមួយរួចហើយ ដោយមិនមានការចូលរួម ឬមានការយល់ព្រម អ្នកអភិវឌ្ឍន៍ ទាមទារអោយមានការប្រាប់ថា គេមិនបានអនុវត្តតាម ការអនុវត្ត ដែលបានព្រមព្រៀងឡើយ ។ អ្នកនៅតែអាចនិយាយ ។ អ្នកនៅតែអាចបញ្ឈប់ ការសាងសង់ ដោយទទួចអោយអ្នកអភិវឌ្ឍន៍គំរោង ផ្តល់អោយ FPIC ចរចារផលប្រយោជន៏ សំរាប់សហគមន៏របស់អ្នក ឬ ផ្លាស់ប្តូរ វិធីដែលគំរោងប្រតិបត្តិការណ៏ ។



## ជំហ៊ានទី ៤:

### ការចរចារបស់ សហគមន៍ ជាមួយអ្នកអភិវឌ្ឍន៍គំរោង

ក្នុងនាមជាសហគមន៍មួយ អ្នកមានសិទ្ធិ ត្រូវបានពិគ្រោះយោបល់ និង ដើម្បីចរចារជាមួយអ្នកអភិវឌ្ឍន៍គំរោង ។ ការពិភាក្សាជាមួយ អ្នកអភិវឌ្ឍន៍ មិនមែនមានន័យថា អ្នកព្រមព្រៀងជាមួយគំរោងទេ ។ ជាសាមញ្ញអ្នកកំពុងតែទាមទារសិទ្ធិរបស់អ្នក ដើម្បីទទួលបានពតិមាន អំពីគំរោង ។ អ្នកអភិវឌ្ឍន៍គំរោង គួរពិគ្រោះយោបល់ជាមួយ សហគមន៍របស់អ្នក នឹងទទួលបាន FPIC របស់អ្នក**មុននឹង ដំណាក់កាលនៃគំរោង ថ្មីនិមួយៗ** ។ នេះមានន័យថា បើសិនជាអ្នកឯកភាព លើផ្នែកមួយនៃគំរោង នៅដំណាក់កាលដំបូង អ្នកអភិវឌ្ឍន៍ត្រូវតែទទួល បាននូវ FPIC របស់អ្នកម្តងទៀត នៅដំណាក់កាលបន្ទាប់ ។ បើសិនជា ការផ្លាស់ប្តូរទីលំនៅអាចត្រូវបានធ្វើឡើង លក្ខខណ្ឌ័ផ្សេងៗត្រូវតែត្រូវបានចរចារ ជាមួយសហគមន៍ មុននឹងការសំរេចចិត្ត ត្រូវបានធ្វើឡើង ។

ការកសាងគំរោងអភិវឌ្ឍន៍ធំៗ រមែងតែនាំមក នូវផលប្រយោជន៍ ហិរញ្ញវត្ថុ សំរាប់អ្នកវិនិយោគ ។ ជាអកុសលសហគមន៍មូលដ្ឋាន ជានិច្ចកាលមិនត្រូវបានផ្តល់ឱកាស ដើម្បីបែងចែកផលប្រយោជន៍ ជាហិរញ្ញវត្ថុ ឬ ផ្សេងទៀតឡើយ ។ ការដាក់យន្តការ ការបែងចែកផលប្រយោជន៍ អាចធានាដល់សហគមន៍ ដែលទទួលរងឥទ្ធិពល ទទួលបានផលប្រយោជន៍ពីគំរោង ។ ឧទាហរណ៍ វាអាចអោយសហគមន៍របស់អ្នក ក្នុងការជ្រើសរើស ពីផលប្រយោជន៍អ្វី ដែលចង់ទទួល ។ វាមានសក្តានុពលធ្វើអោយប្រសើរឡើង នូវជីវភាពរបស់សហគមន៍អ្នក ។ វាបង្ហាញពីរបៀប ដែលគំរោងអាច បន្ថែមគុណតំលៃទៅដល់សហគមន៍ ។

### តើអ្នកណាទទួលខុសត្រូវ?




រមែងតែអ្នកអភិវឌ្ឍន៍គំរោង និង អ្នកដែលទទួលខុសត្រូវ ក្នុងការស្វែងរកការយល់ព្រមរបស់អ្នក គឺជាការរួមគ្នានៃបណ្តាអង្គការខាងលើ ។

### ចំនុចសំខាន់ទី ១:

ស្វែងរកមើលថាតើ មានអង្គការ ដែលជួយលើការងារគ្រប់គ្រងដីធ្លី ឬ ធនធានធម្មជាតិ សំរាប់ប្រទេសជិតខាង ទាំងអស់ដែរឬទេ ។ ឧទាហរណ៍ វាអាចជាអង្គការអភិបាលកិច្ចទន្លេ ដែលធ្វើការនៅក្នុងប្រទេសនិមួយៗ ដែលទន្លេហូរឆ្លងកាត់ ។ បើសិនជាមានពិនិត្យមើលថាតើ រដ្ឋាភិបាលរបស់អ្នក ជាចំណែកនៃអង្គការ នោះដែរឬទេ ។ អ្នកអាចស្វែងរកបន្ថែមទៀត អំពីគំរោងដោយមានការជួយពីពួកគេ ។



## ជំហ៊ានទី ២:

### ស្នើពត៌មានពី អ្នកអភិវឌ្ឍន៍គំរោង

វាជាការសំខាន់ណាស់ក្នុងការដឹង ពីរបៀបដែល គំរោងដែលស្នើឡើង នឹងមានឥទ្ធិពលទៅលើ សហគមន៏របស់អ្នក ។ បន្ទាប់មក អ្នកអាចធ្វើការសំរេចចិត្តដោយ មានការផ្តល់ពតិមានអំពី:

› ថាតើត្រូវផ្តល់ ឬ បដិសេធន៏ ការយល់ព្រម
› ការផ្លាស់ប្តូរ ដែលអ្នកចង់អោយគំរោង រៀបចំឡើង
› លក្ខខណ្ឌ័ដែលអ្នកត្រូវការមុនជួប មុននឹងអ្នកឯកភាពលើគំរោង

វិធីខ្លះដែលគំរោង អាចមានឥទ្ធិពលមកលើសហគមន៏ ត្រូវបានបង្កើតឡើងនៅក្នុងផ្នែក "ការបង្កើត រូបភាព" ហេតុអ្វីមានគោលការណ៏នេះ ហេតុអ្វីនៅពេលនេះ? នៅក្នុងទំព័រទី ៨។

បើសិនជាអ្នកគិតថា សហគមន៏របស់អ្នកអាច ទទួលរងឥទ្ធិពលពីគំរោង អ្នកមានសិទ្ធិក្នុងការស្នើឡើង ឬ ក៏ត្រូវបានផ្តល់ពតិមានពីអ្នកអភិវឌ្ឍន៏គំរោង នៅក្នុងភាសារបស់អ្នក ។ វាមានសារៈសំខាន់ចំពោះ សហគមន៏របស់អ្នក ដើម្បីទទួលបានការផ្តល់ពតិមានពេញលេញ ពីគំរោង ឥទ្ធិពលជាសក្តានុពលរបស់វា និង អ្វីដែលអ្នកអភិវឌ្ឍន៏គំរោង ត្រូវធ្វើដើម្បីការពារ ឬកាត់បន្ថយវា ។

ការស្នើឡើងនូវ ច្បាប់ថតចំឡង ស្តីពីការប៉ាន់ប្រមាណ ពីឥទ្ធិពលសង្គម និង បរិស្ថាន ជាភាសារបស់អ្នក ជាការសំខាន់ ។ នេះអាចជួយធានាដល់សមាជិកសហគមន៏ទាំងអស់ ត្រូវបានទទួលពតិមាន និង យល់ពីឥទ្ធិពលជាចំបង ។ វាអាចជួយក្នុងការ ការពារដំណើរការចរចារ ដែលទាក់ទងទៅ នឹង សមាជិក សហគមន៏ខ្លះ ដែលអាចកេងយកផលប្រយោជន៏ផ្ទាល់ខ្លួនច្រើនជាង ផលប្រយោជន៏សហគមន៏ ។

វាមែនតែមានផ្នែកខ្លះរបស់សហគមន៍ អាចគាំទ្រគំរោង ខណៈដែលផ្នែកដទៃទៀតរបស់សហគមន៍ បានជំទាស់ទៅលើគំរោងនោះ ។ អ្នកអភិវឌ្ឍន៍គំរោងខ្លះអាចនឹងខិតខំបែងចែក ដោយបញ្ចូលទៅក្នុងក្រុមស្រប និងក្រុមប្រឆាំងជំទាស់ ។ នេះអាចធ្វើអោយអន្តរាយដល់ សមត្ថភាពសហគមន៍ ក្នុងការរួមគ្នា ធ្វើសេចក្តីសំរេចចិត្តលើគំរោង និងអាចដឹកនាំលើអ្វី ដែលកំពុងកើតមានឡើង នៃភាពតានតឹងក្នុងសហគមន៍ ។ វាអាចទៅរួច ដែលសហគមន៍ខ្លះ នឹងទទួលរងឥទ្ធិពល ដោយសារគំរោង ប៉ុន្តែក៏មានសហគមន៍មួយនោះ អាចទទួលរងឥទ្ធិពលខ្លាំងជាងសហគមន៍ដទៃទៀត ។ ប្រសិនបើ ពិនិត្យមើលអោយសព្វគ្រប់ វាជាការសំខាន់ដើម្បីខិតខំ អភិវឌ្ឍន៍លើមធ្យោបាយរួម ជាមួយសហគមន៍ដទៃទៀត អញ្ចឹងឥទ្ធិពលអាក្រក់ វាជាហេតុដែលបណ្តាលអោយសហគមន៍ ត្រូវតែមានការបញ្ចេញសំលេងមតិខ្លាំង ដើម្បីទប់ទល់ ។



## ជំហ៊ានទី ៣៖

### ធ្វើការពិភាក្សា នៅក្នុងសហគមន៍របស់អ្នក

នៅពេលដែលអ្នក ទាក់ទងជាមួយអ្នកអភិវឌ្ឍន៍គំរោង អ្នកគួរតែចាប់ផ្តើមធ្វើការពិភាក្សា ពីគំរោងលំអិត នៅក្នុងសហគមន៍របស់អ្នក ។ សហគមន៍ទាំងមូលគួរតែត្រូវបានផ្តល់ពតិមាន អំពីគំរោង ដែលស្នើឡើង ។ ឧបករណ៍ ដូចជា ផែនទី ខិតបណ្ណ័ ផ្ទាំងរូបភាព និង វីដេអូ អាចត្រូវបានប្រើប្រាស់ក្នុង ការផ្តល់ពតិមាន ទៅដល់សមាជិកសហគមន៍ទាំងអស់ ។ នេះអាចធានាអោយអ្នកទាំងអស់គ្នាយល់ ពីផលប្រយោជន៍ និង ឥទ្ធិពល ជាចំបងរបស់គំរោងដែលអាចមាន ។ សហគមន៍របស់អ្នកគួរតែសំរេចលើអ្វីដែលសំខាន់ ។ បន្ទាប់មកតំណាងសហគមន៍របស់អ្នក អាចចរចារជាមួយ អ្នកអភិវឌ្ឍន៍ គំរោងបើសិនជា អ្វីដែលសហគមន៍សំរេច គួរតែជាជំហ៊ានបន្ទាប់ ។

នៅពេលដែលពិភាក្សាលើអ្វីដែលអ្នកចង់បាន ប្រើប្រាស់ការអនុវត្តដែលអាចទទួលយកបានដើម្បីឈាន ទៅដល់ការព្រមព្រៀង ។ វាជាការសំខាន់ណាស់ក្នុងការយកចិត្តទុកដាក់ទៅលើ គំនិតរបស់សហគមន៍ទាំងអស់ ដែលអាចទទួលរងឥទ្ធិពល ។ ត្រូវធានាថាសមាជិកសហគមន៍ទាំងអស់ រួមទាំងស្រ្តី និង យុវជន ត្រូវបានចូលរួមនៅក្នុង ដំណើរការធ្វើសេចក្តីសំរេចចិត្ត ។ នេះដោយសារតែគំរោងខ្នាតធំ មានឥទ្ធិពលទៅលើ មនុស្សផ្សេងៗ ខុសៗគ្នា ។

វារមែងតែមានសហគមន៍ច្រើនទទួលរងឥទ្ធិពលពីគំរោងមួយ ។ អ្នកអភិវឌ្ឍន៍គំរោងត្រូវតែប្រាប់អ្នកអំពីការ ព្រមព្រៀងដែលធ្វើឡើងសំរាប់សហគមន៍ វាអាចមានសារៈសំខាន់ក្នុងការស្វែងរកបើសិនជាមានសហគមន៍ណាមួយ ត្រូវបានទទួលរងឥទ្ធិពលដោយគំរោងដូចគ្នា ដែលសហគមន៍ របស់អ្នកមានកង្វល់អំពីបញ្ហានោះដែរ ។ អ្នកអាចធ្វើការរួមគ្នា ដើម្បីចរចារជាមួយអ្នកអភិវឌ្ឍន៍គំរោង ឬ រដ្ឋាភិបាល ។

#### ចំនុចសំខាន់ទី ៣៖

អ្នកមិនត្រូវធ្វើការសំរេចចិត្តណាមួយ នៅក្នុងដំណាក់កាលនេះទេ ។ ការសំរេចចិត្តទីមួយរបស់អ្នក អាចថា អ្នកត្រូវការពតិមានបន្ថែម ពីអ្នកអភិវឌ្ឍន៍គំរោង ។

**វាមានសារៈសំខាន់ណាស់ក្នុងការទទួលបានពត៌មានដែលល្អ អំពីវិសាលភាពភូមិសាស្ត្ររបស់គំរោង និង ដើម្បីធានាថា អ្នកអភិវឌ្ឍន៍គំរោងកំណត់យ៉ាងត្រឹមត្រូវនូវ សហគមន៍ដែលទទួលរងឥទ្ធិពល ។ បើសិនជាសហគមន៍របស់អ្នក មិនត្រូវបានធ្វើការពិចារណាជាសហគមន៍ ដែលទទួលរងឥទ្ធិពលជាសក្តានុពល ដោយអ្នកអភិវឌ្ឍន៍គំរោងនោះទេ អ្នកអភិវឌ្ឍន៍ អាចព្យាយាម គេចពីការចរចារ និងការពិគ្រោះយោបល់ ជាមួយសហគមន៍អ្នក ។**

វិធីមួយពីការទទួលបានពតិមានទាំងនេះគឺ សួរទៅដល់អ្នកអភិវឌ្ឍន៍គំរោង ។ អ្នកអាចកត់ត្រាពតិមានទាំងនេះ និងយកវាទៅពិភាក្សា ជាមួយសហគមន៍អ្នក ។ ប្រអប់នៅក្នុងទំព័របន្ទាប់ ផ្តល់នូវសំនួរសំខាន់ៗខ្លះដើម្បីសួរ ។ អ្នកក៏អាចសួរផ្ទាល់ទៅដល់មន្ទីរ របស់រដ្ឋាភិបាល នៅក្នុងប្រទេសរបស់អ្នក ។ ទាំងនោះរួមមាន មន្ទីរ បរិស្ថាន រ៉ែ ព្រៃឈើ និង កសិកម្ម ឬ ហិរញ្ញវត្ថុ ។ នេះអាចខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ។ សហគមន៍របស់អ្នកអាចទទួលរងឥទ្ធិពល ទោះជាគំរោងនោះ មិនស្ថិតនៅក្នុងតំបន់ជិតអ្នកក៏ដោយ ។ ឧទាហរណ៏៖ ការបំពុលទឹក ដោយការអភិវឌ្ឍន៍ ដែលអាចរាយប៉ាយ និង មានឥទ្ធិពលមកលើ សហគមន៍ ដែល រស់នៅក្រៅពីតំបន់គំរោងផ្ទាល់ ។ ទំនប់អាចរាំងស្ទាក់ត្រីដែលនឹងមានឥទ្ធិពលដល់ ប្រភពអាហារ និង ការរស់នៅរបស់អ្នក ។

**គួរចងចាំ៖** ទោះជាគំរោងដែលស្ថិតនៅក្នុងប្រទេសផ្សេងក៏ដោយ ក៏អាចមានឥទ្ធិពលមកលើ សហគមន៍ របស់អ្នកដែរ ។ ឧទាហរណ៏ ការជីករ៉ែនៅក្នុងប្រទេសមួយផ្សេង អាច បង្ហូរកាកសំណល់របស់វា នៅក្នុងទន្លេដែលហូរកាត់ប្រទេសរបស់អ្នក ហើយសហគមន៍របស់អ្នក ពឹងផ្អែកទៅលើទឹកនោះ ។

#### ចំនុចសំខាន់ទី ២៖

អ្នកអាចស្នើ ពតិមានពីគំរោងជាភាសា នឹង នៅក្នុងទំរង់ ដែលអាចយល់បាន ចំពោះសហគមន៍របស់អ្នក ។

## សំនួរអំពីគំរោង

- តើអ្វីទៅជាគំរោង? តើវានឹងធ្វើអ្វី?
- តើគំរោងមានទំហំប៉ុណ្ណា? តើវានឹងកសាងនៅពេលណា? តើវាប្រតិបត្តិការណ៏មានរយៈពេលប៉ុន្មាន?
- តើអ្នកណាជាអ្នកអភិវឌ្ឍន៏គំរោង? (ឧទាហរណ៏ ក្រុមហ៊ុនឯកជន, រដ្ឋាភិបាល)
- តើប្រវត្តិ ឬ ការអនុវត្តពីមុនរបស់ក្រុមហ៊ុនមានអ្វីខ្លះ?
- តើគេមានកេរ្តិ៏ឈ្មោះល្អ ឬ មិន ល្អ ?
- តើអ្នកណាជាអ្នកផ្តល់ទុនកំចី? (ឧទាហរណ៏ ធនាគារពាណិជ្ជ, ធនាគារពិភពលោក, មូលនិធិ វិនិយោគ
- តើមុខជំនួញចំបងរបស់ អ្នកអភិវឌ្ឍន៏គំរោងចំបង គឺអ្វី?
- តើអ្នកអភិវឌ្ឍន៏គំរោង ជាជនជាតិអ្វី?
- តើអ្វី នឹងត្រូវបានកសាងចំពោះគំរោង (ឧទាហរណ៏ ផ្លូវ ទំនប់ បង្គោលអគ្គិសនីធំៗ)
- តើអ្នកណា នឹង ចូលរួមនៅក្នុងគំរោង បន្ថែមលើ ក្រុមហ៊ុន ឬ រដ្ឋាភិបាល (ឧទាហរណ៏ អ្នកផ្គត់ផ្គង់ និង អ្នកលទ្ធកម្ម)
- តើរដ្ឋាភិបាលផ្តល់ការគាំទ្រអ្វីខ្លះ? (ឧទាហរណ៏ គ្មានការបន្ថយពន្ធដារ ចំពោះអ្នកអភិវឌ្ឍន៏គំរោងកាត់បន្ថយ ការគិតថ្លៃការទទួលបាន និង ប្រើប្រាស់ ដី)
- តើស្ថាប័នដឹកនាំមូលដ្ឋាន មានគំនិតយ៉ាងដូចម្តេចទាក់ទងទៅ នឹងគំរោង ?

***កំណត់សំគាល់:*** *ទាំងនេះគ្រាន់តែជាសំនួរដែលស្នើឡើង ។ វាអាចមានសំនួរជាច្រើនទៀត ដើម្បីសួរដល់អ្នកអភិវឌ្ឍន៏គំរោង ដែលទាក់ទងជាពិសេសទៅដល់ គំរោងសហគមន៏របស់អ្នក វប្បធម៌ និង ជំនឿ ។*

# សំនួរសំខាន់ៗ សំរាប់សួរ អ្នកអភិវឌ្ឍន៍គំរោង

## ឥទ្ធិពលគំរោង

- តើដីអ្វីដែលទទួលរង ផលប៉ះពាល់?
- តើមានផែនទីណាមួយដែលបង្ហាញពី ដីដែលទទួលរងឥទ្ធិពលដែរឬទេ?
- តើនឹងមានឥទ្ធិពលណាមួយ ទៅដល់ដីនិងធនធានផ្សេងទៀត ជានិរន្តដែរឬទេ?
- តើអ្នកអភិវឌ្ឍន៏គំរោង ធ្វើការប៉ាន់ប្រមាណ ពី ឥទ្ធិពលសិទ្ធិមនុស្ស បរិស្ថាន យេនឌ័រ និង សង្គមដែរឬទេ?
- តើអ្វីជាហានិភ័យជាចំបងរបស់គំរោង? (ឧទាហរណ៏ ការបំពុល ឬ ការចូលទៅក្នុងតំបន់ ហាមឃាត់)
- តើមានរបាយការណ៏ឯករាជ្យណាមួយ ដែលលំអិតពីហានិភ័យទាំងនោះ ហើយអាចរកបានដោយសហគមន៏ ?
- តើអ្វីដែល នឹងជាផលប្រយោជន៏ សំរាប់សហគមន៏មូលដ្ឋាន ?
- តើផលប្រយោជន៏នោះជានិរន្ត ឬ បណ្តោះអាសន្ន?
- តើអ្វីដែលក្រុមហ៊ុន ផ្តល់វិភាគទានទៅដល់សហគមន៏ (ឧទាហរណ៏ សាលា ផ្លូវ មន្ទីពេទ្យ និង កម្មវិធីអភិវឌ្ឍន៏សង្គមផ្សេងៗទៀត )
- តើគំរោងចូលរួមវិភាគទាន ធ្វើអោយការកាន់កាប់ ដីសហគមន៏ មានសុវត្ថិភាពដែរឬទេ? បើសិនជាអ្នកអភិវឌ្ឍន៏គំរោងយកដីរបស់យើង តើគេមានសំណង ដោយអោយដីកន្លែងថ្មីមក យើងដែរឬទេ?

## ការចរចារ និង ពិគ្រោះយោបល់ជាមួយសហគមន៍

- តើសហគមន៏នឹងមានឱកាសអ្វី ក្នុងការផ្តល់យោបល់ដល់ការរៀបចំគំរោង? តើវា នឹងត្រូវបានគ្រប់គ្រងយ៉ាងដូចម្តេច?
- តើសហគមន៏ អាចចូលរួមនៅក្នុងដំណើរការ ការប៉ាន់ប្រមាណលើ ឥទ្ធិពលសង្គម និង បរិស្ថានយ៉ាងដូចម្តេច?
- តើអ្នកណាធ្វើការប៉ាន់ប្រមាណលើ ឥទ្ធិពល សង្គម និង បរិស្ថាន ហើយគេបានបកប្រែ ជាភាសាមូលដ្ឋានដែរឬទេ?
- តើក្រុមហ៊ុនបានធ្វើការពិគ្រោះយោបល់ជាមួយនរណា?
- តើក្រុមហ៊ុនគិតថា គេទទួលបានការយល់ព្រម ពីសហគមន៏ដែរឬទេ?
- តើដំណើរការអ្វី នឹងត្រូវអនុវត្តតាម បើសិនជាមានការផ្លាស់ប្តូរការរៀបចំគំរោង?
- តើក្រុមហ៊ុនធ្វើការចរចារជាមួយ សហគមន៏នៅក្នុង ដំណាក់កាលនិមួយៗនៃគំរោងដែរឬទេ?
- តើអ្នកអភិវឌ្ឍន៏គំរោង ឆ្លើយតបទៅនឹង កង្វល់របស់សហគមន៏ យ៉ាងដូចម្តេច?
- តើអ្នកអភិវឌ្ឍន៏គំរោង បានរៀបចំបើកចំហរ ផលចំណេញ និង ការចំណាយដែលទាក់ទងទៅនឹង គំរោងដែរឬទេ?
- តើផលចំណេញពីគំរោង នឹងយកទៅណា?





OXFAM